NUM
2024

ឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា

ហ៊ឹម សុវណ្ណដារ៉ា

ក្រសួងអប់រំ យុវជន និងកីឡា
សាកលវិទ្យាល័យជាតិគ្រប់គ្រង
សាលាក្រោយបរិញ្ញាបត្រ

# ឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា

ហ៊ឹម សុវណ្ណដារ៉ា

និក្ខេបបទដើម្បីបំពេញលក្ខខណ្ឌប្រលងបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

ជំនាញ៖ រដ្ឋបាលសាធារណៈ

ភ្នំពេញ
ឆ្នាំ២០២៤

**ក្រសួងអប់រំ យុវជន និងកីឡា**

**សាកលវិទ្យាល័យជាតិគ្រប់គ្រង**

**សាលាក្រោយបរិញ្ញាបត្រ**

# ឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា

**ហ៊ឹម សុវណ្ណដារ៉ា**

និក្ខេបបទដើម្បីបំពេញលក្ខខណ្ឌប្រលងបញ្ចប់
ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

សាស្ត្រាចារ្យដឹកនាំ

**បណ្ឌិត ហេង សុភាព**

**ភ្នំពេញ**
ឆ្នាំ២០២៤

# លិខិតធានាអះអាង

ខ្ញុំបាទ សូមធានាអះអាងថា រាល់ខ្លឹមសារ និងការលើកឡើងក្នុងកិច្ចការ ស្រាវជ្រាវមួយនេះ គឺមានការបង្ហាញពីប្រភពដើម និងឯកសារយោងច្បាស់លាស់ ដែលសុទ្ធសឹងជាស្នាដៃស្រាវជ្រាវរបស់ខ្ញុំបាទផ្ទាល់ ដោយឥតមានការចម្លងចេញពី កិច្ចការរបស់អ្នកដទៃទៀយ។ ទាំងអស់នេះ គឺជាការចងក្រងស្នាដៃថ្មីមួយរបស់ខ្ញុំបានក្នុងការខិតខំ ចងក្រង ប្រមូលឯកសារ និងរាល់ទិន្នន័យដែលពាក់ព័ន្ធ ដើម្បីបំពេញ លក្ខខណ្ឌក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឱ្យបានជោគជ័យ។

ហ៊ឹម សុវណ្ណដារ៉ា

សាកលវិទ្យាល័យជាតិគ្រប់គ្រង

ភ្នំពេញ

២០២៤

# សេចក្តីថ្លែងអំណរគុណ

**ខ្ញុំបាទឈ្មោះ ហ៊ឹម សុវណ្ណដារ៉ា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញរដ្ឋបាលសាធារណៈនៃសាកលវិទ្យាល័យ ជាតិគ្រប់គ្រងឆ្នាំសិក្សា ២០២១-២០២៣។ អស់រយៈពេលជិត២ឆ្នាំនៃការសិក្សានៅសាកលវិទ្យាល័យ ខ្ញុំបាទបានឆ្លងកាត់នូវការខិតខំប្រឹងប្រែងដ៏ស្វិតស្វាញបំផុត ដោយចំណាយទាំងពេលវេលា កម្លាំងកាយ ប្រាជ្ញា ស្មារតីគ្រប់បែបយ៉ាងដើម្បីទទួលបាននូវលទ្ធផលជោគជ័យ និងសម្រេចបាននូវការរៀបចំសារណាបញ្ចប់ការសិក្សាមួយ ដែលប្រកបដោយផ្លែផ្កា។ តាមរយៈលទ្ធផលវិជ្ជមាននោះ យើងខ្ញុំសូមថ្លែងអំណរគុណ និងសម្តែងនូវកត្តញ្ញូតាធម៌ ការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖

**អ្នកម្តាយ ហ៊ឹម មុំ ជា** ទីគោរព និងជាអ្នកមានគុណដ៏ខ្ពង់ខ្ពស់មិនអាចកាត់ថ្លៃបាន។ លោកបានពុះពារគ្រប់ឧបសគ្គដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្គត់ផ្គង់ទំនុកបម្រុង ទាំងសម្ភារៈ ហិរញ្ញវត្ថុ និងស្មារតីក្នុងការសិក្សា ព្រមទាំងជាទីប្រឹក្សាផ្តល់យោបល់ដ៏សំខាន់បំផុតតាំងពីកូនចូលសិក្សាថ្នាក់បឋមរហូតបញ្ចប់ថ្នាក់ឧត្តមសិក្សាយ៉ាងជោគជ័យ។ គុណដ៏ធំធេងរបស់លោកអ្នកមានគុណ កូននឹងខិតខំតបស្នងឱ្យអស់ពីកម្លាំងកាយ កម្លាំងចិត្តនៅថ្ងៃខាងមុខ ជាងនេះទៅទៀតខ្ញុំបាទនឹងប្តេជ្ញាចិត្តថានឹងធ្វើតែអំពើល្អ ជួយកិច្ចការសង្គមជាតិ ធ្វើខ្លួនជាប្រជាពលរដ្ឋល្អ និងក្លាយជាធនធានមនុស្សដែលសង្គមជាតិកំពុងត្រូវការមិន អាចខ្វះបាន។

ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ដែលបានគ្រប់គ្រង ដឹកនាំ បង្ហាត់ បង្រៀនទាំងទ្រឹស្តី និងការអនុវត្តផ្ទាល់ប្រកបដោយការយកចិត្តទុកដាក់ និងទំនួលខុសត្រូវខ្ពស់ចំពោះនិស្សិតគ្រប់រូប ដោយពុំគិតពីការលំបាកនឿយហត់អ្វីឡើយ ផ្ទុយទៅវិញលោកមានតែខិតខំណែនាំ អប់រំ ប្រៀនប្រដៅ និងផ្តល់ដំបូន្មានល្អៗ ដល់និស្សិតគ្រប់រូបប្រកបដោយបទពិសោធន៍ និងទំនួលខុសត្រូវខ្ពស់ ក្នុងគោលដៅអភិវឌ្ឍន៍ ធនធានមនុស្សប្រកបដោយថាមពល និងចំណេះដឹងពិតប្រាកដដែលសង្គមជាតិត្រូវការ។

ជាពិសេសយើងខ្ញុំសូមគោរពការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សាស្ត្រាចារ្យបណ្ឌិត **ហេង សុភាព** ដែលលោកបានចំណាយពេលវេលាដ៏មានតម្លៃ ដើម្បីផ្តល់នូវការណែនាំគន្លឹះសំខាន់ៗក្នុងការ ស្រាវជ្រាវ និងរៀបចំការសរសេរនិក្ខេបបទ មតិយោបល់ និងកែសម្រួលនិក្ខេបបទរបស់ខ្ញុំបាទ ដោយពុំខ្លាចនឿយហត់ដោយគ្មានការលាក់លៀម ប្រកបដោយស្នាមញញឹម និងក្តីស្រលាញ់ចំពោះនិស្សិត។

## ព្រមទាំង

សាស្ត្រចារ្យទាំងអស់នៃសាកលវិទ្យាល័យជាតិគ្រប់គ្រងដែលបានផ្តល់ចំណេះដឹងគ្រប់មុខវិជ្ជារួមទាំងដំបូន្មានល្អៗ ជាច្រើនដល់យើងខ្ញុំអស់រយៈពេលសិក្សា ២ឆ្នាំ កន្លងមកនេះ។

# សេចក្តីសង្ខេប


កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា បានអភិវឌ្ឍជាបន្តបន្ទាប់ដើម្បីកែលម្អរបៀបគ្រប់គ្រងហិរញ្ញវត្ថុឲ្យមានលក្ខណល្អប្រសើរ។ បន្ទាប់ពីបញ្ចប់ជម្លោះសង្គ្រាមស៊ីវិលក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាបានចាប់ផ្តើមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ២០០៤ ហើយជាបន្តបន្ទាប់កម្មវិធីនេះ បានធ្វើឲ្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាមាននូវថវិកាមានជឿជាក់ ការកែលម្អគណនេយ្យភាពហិរញ្ញវត្ថុ ការភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ដែលធ្វើឱ្យសម្រេចគោលដៅរួម និងការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អាចជួយឲ្យរាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់ធនធានប្រកបប្រសិទ្ធភាព តម្លាភាព ព្រមទាំងមានជំនឿទុកចិត្តពីសាធារណជន និងម្ចាស់ជំនួយ។

បន្ថែមពីនេះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានចក្ខុវិស័យ ប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ។ ជាមួយគ្នានេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈធានាឱ្យថវិកាអាចវិភាជ និងប្រើប្រាស់ដល់ក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។

បច្ចុប្បន្ននេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ **គ.ហ.ស.** និងសម្របសម្រួលការងារជាមួយក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង-ស្ថាប័ន (**ក.ហ.ស.**) និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងសម្របសម្រួលការងារជាមួយកំណែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ **អ.គ.ហ.** ក៏មានតួនាទីផ្តល់ការគាំទ្រជូនក្រសួង ស្ថាប័ន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សរុបមក កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ** .......... ii

**សេចក្តីសង្ខេប** .......... iii

**បញ្ជីតារាង** .......... vii

**បញ្ជីក្រាហ្វិច** .......... viii

**ជំពូកទី១ សេចក្តីផ្តើម** .......... ១

១.១. សាវតានៃការសិក្សាស្រាវជ្រាវ .......... ១

១.២. ការថ្លែងបញ្ហា .......... ៣

១.៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ .......... ៦

១.៤ សំណួរនៃការសិក្សាស្រាវជ្រាវ .......... ៦

១.៥. កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ .......... ៦

១.៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ .......... ៦

១.៧. វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ .......... ៧

១.៨ ប្លង់នៃការសិក្សាស្រាវជ្រាវ .......... ៨

**ជំពូកទី២ រំលឹកទ្រឹស្តី** .......... ១០

២.១. សេចក្តីផ្តើម .......... ១០

២.២.ការរំលឹកទ្រឹស្តី .......... ១០

២.២.១.ភាពជឿជាក់នៃថវិកា .......... ១០

២.២.២.គណនេយ្យភាពហិរញ្ញវត្ថុ .......... ១០

២.២.៣.ការភ្ជាប់ថវិកាទៅនឹងគោលនយោបាយ .......... ១១

២.២.៤.គណនេយ្យភាពសមិទ្ធកម្ម .......... ១១

២.២.៥.កម្មវិធីកំណែទម្រង់ប្រកបដោយនិរន្តរភាព .......... ១២

២.៣.ក្របខ័ណ្ឌការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ .......... ១២

២.៣.១. ចក្ខុវិស័យ .......... ១២

២.៣.២.យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......... ១២

២.៤. ពាក្យគន្លឹះ .......... ១៥

២.៥. ទិដ្ឋភាពទូទៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា .................. ១៧
២.៥.១. ភាពជឿទុកចិត្តនៃថវិកា ........................................................................ ១៧
២.៥.២. ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ........................................................ ១៨
២.៥.៣. ប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ........................... ១៨
២.៥.៤. កសាងគណនេយ្យភាពសមិទ្ធកម្ម.............................................................. ១៩
២.៥. ស្នូលសំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា................. ១៩
២.៥.១. ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ...................................................... ១៩
២.៥.២. ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ.................................................... ២០
២.៥.៣.ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ............... ២១
២.៥.៤.ការកសាងគណនេយ្យភាពសមិទ្ធកម្ម ......................................................... ២១
២.៥.៥.ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត ........................................................................................ ២២
២.៦. ការសិក្សាសម្មតិកម្ម ................................................................................... ២៣
២.៧. ការរំលឹកវិធីសាស្ត្រស្រាវជ្រាវ ....................................................................... ២៥
**ជំពូកទី៣ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**.................. ២៥
៣.១.ទិដ្ឋភាពទូទៅ ........................................................................................... ២៦
៣.២. រចនាសម្ព័ន្ធ និងយន្តការ ........................................................................... ២៨
៣.២.១.រចនាសម្ព័ន្ធ............................................................................................. ២៨
៣.២.២. យន្តការស្ថាប័ន ......................................................................................... ២៩
២.៣.២.៥.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ................................................................................................ ៣១
៣.៣. សមត្ថភាពស្ថាប័ន ..................................................................................... ៣២
៣.៣.១. ការបន្តជំរុញភាពជាម្ចាស់ នឹងឆន្ទៈ នៃការចូលរួមកម្មវិធីកែទម្រង់ ................. ៣៣
៣.៣.២.ការបន្តពង្រឹងការរៀបចំក្របខ័ណ្ឌកសាងសមត្ថភាពធនធានមនុស្ស៖ ............. ៣៤
**ជំពូកទី៤ វិធីសាស្ត្រស្រាវជ្រាវ** ........................................................... ៣៥
៤.១.សេចក្តីផ្តើម ............................................................................................. ៣៥

៤.២.ការជ្រើសរើសសំណាក និងប៉ាន់គំរូ ........................................ ៣៥
៤.៣.ប្រភពទិន្នន័យ ........................................ ៣៥
៤.៤.ឧបករណ៍ក្នុងការវិភាគទិន្នន័យ ........................................ ៣៥
៤.៥.វិធីសាស្ត្រក្នុងការជ្រើសរើសគំរូ ........................................ ៣៦
៤.៦.នីតិវិធីក្នុងការប្រមូលទិន្នន័យ ........................................ ៣៦
៤.៧.ភាពជឿជាក់នៃទិន្នន័យ ........................................ ៣៧
**ជំពូកទី៥ ការវិភាគទិន្នន័យ** ........................................ ៣៩
៥.១.សេចក្តីផ្តើម ........................................ ៣៩
៥.២. ពត៌មានទូទៅរបស់អ្នកផ្តល់សម្ភាសន៍ ........................................ ៣៩
៥.២.១ ភេទរបស់អ្នកផ្តល់សម្ភាសន៍ ........................................ ៣៩
៥.២.២ អាយុរបស់អ្នកផ្តល់សម្ភាសន៍ ........................................ ៤០
៥.២.៣ មុខរបររបស់អ្នកផ្តល់សម្ភាសន៍ ........................................ ៤០
៥.៣.ការវាយតម្លៃកត្តាដែលមានឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........................................ ៤០
៥.៤.ឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ........................................ ៤១
**ជំពូកទី ៦ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍** ........................................ ៤៧
៦.១.សេចក្តីផ្តើម ........................................ ៤៧
៦.២ សង្ខេបលទ្ធផលដែលរកឃើញ ........................................ ៤៧
៦.៣ សេចក្តីសន្និដ្ឋាន ........................................ ៤៧
៦.៤ អនុសាសន៍ ........................................ ៤៨
៦.៥ ការស្រាវជ្រាវនាអនាគត ........................................ ៤៨
**ឯកសារយោង** ........................................ ៥០
**ឧបសម្ព័ន្ធ** ........................................ ៥៣

# បញ្ជីតារាង

**តារាងទី 1** ៖Dimensions Sub Dimensions Study....................................................២៤
**តារាងទី 2** ៖កម្រិតជឿជាក់នៃទិន្នន័យអាល់ហ្វា ........................................................... ៣៧
**តារាងទី 3** ៖អាល់ហ្វា (ភាពជឿជាក់នៃទិន្នន័យ)..........................................................៣៨
**តារាងទី 4** ៖មធ្យមភាគ និងបម្រែបម្រួលស្តង់ដានៃសម្មតិកម្ម........................................... ៤១
**តារាងទី 5** ៖ការវិភាគតាមសមីការ ...................................................................... ៤២

# បញ្ជីក្រាហ្វិច

**ក្រាហ្វិកទី 1** ៖ ទិន្នន័យភេទរបស់អ្នកផ្តល់សម្ភាសន៍ ........................................................ ៣៩
**ក្រាហ្វិកទី 2** ៖ ទិន្នន័យអាយុរបស់អ្នកផ្តល់សម្ភាសន៍ ........................................................ ៤០

# ជំពូកទី១
# សេចក្ដីផ្ដើម

## ១.១. សាវតានៃការសិក្សាស្រាវជ្រាវ

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា មានស្នូលយុទ្ធសាស្ត្រ គឺការកែទម្រង់ និងការពង្រឹងអភិបាលកិច្ចល្អ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ក្នុងការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ (រាជរដ្ឋាភិបាលកម្ពុជា,២០១៨ និង រាជរដ្ឋាភិបាលកម្ពុជា,២០២៣)។ ដើម្បីឆ្លើយតបជាមួយនឹងយុទ្ធសាស្ត្រទាំងពីរនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញកម្មវិធីកែទម្រង់ក្នុងការការបង្កើនគុណភាពអភិបាលកិច្ច ឬការកែទម្រង់លើរចនាសម្ព័ន្ធ ឬការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធដែលមានចំនួន ៤ រួមមាន៖ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្រោមការដឹកនាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈក្រោមការដឹកនាំរបស់ក្រសួងមុខងារសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ក្រោមការដឹកនាំរបស់ក្រសួងយុត្តិធម៌ ដើម្បីធានាចីរភាពនៃរដ្ឋបាលសាធារណៈ ប្រសិទ្ធភាពនៃសេវាសាធារណៈ និងសុខមាលភាពនិងជីវភាពកាន់តែប្រសើររបស់ប្រជាពលរដ្ឋ (រាជរដ្ឋាភិបាលកម្ពុជា,២០២២)។

ជាមួយគ្នានេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចូលរួមពង្រឹងគុណភាពអភិបាលកិច្ចល្អ និងការកសាងប្រព័ន្ធហិរញ្ញវត្ថុរឹងមាំមួយ ក្នុងការលើកកម្ពស់ជីវភាព និងបម្រើសេវាសាធារណៈជូនប្រជាជនបានកាន់ប្រសើរតាមរយៈការអភិវឌ្ឍន៍ធនធានមនុស្សកាន់តែមានគុណភាព ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជាប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធអគ្គិសនី ការកសាងសាលារៀន និងមន្ទីរពេទ្យមានចំនួនច្រើន និងមានគុណភាពកាន់តែប្រសើរឡើងជាដើម។ ទទឹមនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកែទម្រង់ចំនួន ៤ ដំណាក់កាល និងឆ្លុះបញ្ចាំងតាមរយៈផែនការសកម្មភាពរួមមួយ តាមដំណាក់កាលនីមួយៗ (រាជរដ្ឋាភិបាលកម្ពុជា,២០២៣)។

នៅឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការដឹកនាំក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំ និងការធ្វើកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ប្រទេសកម្ពុជា។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះ បានធ្វើការវិវត្តន៍ពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ ដោយធានាបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព តម្លាភាព គណនេយ្យភាព និងអភិបាលកិច្ចល្អនៅកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា, ២០០៤)។

កាលពីនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១ ដែលគោលដៅចម្បង គឺ "**ការបង្កើនភាពជឿទុកចិត្តនៃថវិកា**" ដោយផ្តល់អាទិភាពបន្ទាន់លើការងារពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ជាមួយគ្នានេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់

កាលទី១ បានដាក់ចេញនិងជំរុញការអនុវត្តវិធានការជាច្រើន ដែលនាំឱ្យយើងសម្រេចដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ (រាជរដ្ឋាភិបាលកម្ពុជា, ២០០៨)។

បន្ទាប់ពីបានអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអស់រយៈពេល ៤ឆ្នាំ ដែលកម្មវិធីនេះ បានបង្កើននូវភាពជឿទុកចិត្តនៃថវិកាត្រូវបានសម្រេចជាមូលដ្ឋានអាចឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចនូកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២។ កាលនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដែលមានគោលដៅចម្បង គឺ"**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**" ដោយផ្តោតជាសំខាន់លើការរៀបចំការកែលម្អ ព្រមទាំងការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដាអន្តរជាតិ ទន្ទឹមនឹងត្រូវពង្រឹងភាពជឿទុកចិត្តនៃថវិកា ឱ្យកាន់តែរឹងមាំបន្ថែមទៀត ជាពិសេសលើការពង្រឹងការព្យាករណ៍ចំណូល-ចំណាយឱ្យកាន់តែមានសុក្រឹត។ ក្នុងរយៈពេល ៦ឆ្នាំ (២០០៩-២០១៥) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ បានការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុដោយសម្រេចបានមូលដ្ឋានជាសារវន្តនៃគណនេយ្យភាពហិរញ្ញវត្ថុដែលមានជាអាទិ៍ ការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី មាតិកាថវិកាថ្មី ថវិកាកម្មវិធី ផែនការយុទ្ធសាស្រ្តថវិកា អង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(ចក្ខុវិស័យ និងយុទ្ធសាស្រ្តស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣, រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១៦)។

បន្ទាប់ពីបញ្ចប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ រយៈពេល ៦ឆ្នាំមក រាជរដ្ឋាភិបាលកម្ពុជាបានដាក់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ កាលពីថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ដែលមានគោលដៅចម្បង គឺ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" បានបង្ហាញថាការកែទម្រង់របស់យើង បានបោះជំហានដ៏សំខាន់មួយថ្មីទៀត គឺការចាប់ផ្តើមធ្វើការផ្លាស់ប្តូរមួយចំណែកម្តងៗ នៃប្រព័ន្ធថវិកាបច្ចុប្បន្ន តាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ស្តង់ដារគណនេយ្យ និងប្លង់គណនេយ្យថ្មី អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី រួមជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី១ ព្រមទាំងការចាប់ផ្តើមពង្រឹងនិងពង្រីកប្រព័ន្ធថវិកាកម្មវិធីពេញលេញជាជំហានៗ ទៅក្នុងចំណោមក្រសួង-ស្ថាប័នរដ្ឋបាលគ្រប់ថ្នាក់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីឆ្នាំ២០១៥ ទៅរហូតដល់ឆ្នាំ២០១៨ ស្របតាម "**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្រ្តនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០**" ក្នុងគោលដៅបោះជំហាន ឆ្ពោះទៅកាន់ការកែប្រែប្រព័ន្ធថវិកាទាំងស្រុងពី "**ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ**" ឱ្យបាននៅឆ្នាំ២០២០។ ការរៀបចំការផ្លាស់ប្តូរនេះ គឺជាការងារស្នូល នៃដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកំណត់យកការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយជាគោលដៅចម្បង។ ជាលទ្ធផលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ បានចំណាយអស់រយៈពេលប្រហែល៧ឆ្នាំ គិតចាប់ពីឆ្នាំ២០១៦ រហូតដល់ ឆ្នាំ២០២២ ដោយសម្រេចបាននូវចូលដ្ឋានគ្រឹះសំខាន់ៗ ដូចជាការដាក់ឱ្យអនុវត្តជាផ្លូវការនូវការកែទម្រង់ថ្មីនៃប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងការដាក់ឱ្យអនុវត្តថវិកាកម្មវិធី

ពេញលេញនៅគ្រប់ក្រសួង ស្ថាប័ន និងនៅតាមបណ្តារដ្ឋបាលរាជធានី និងខេត្តទាំង២៥ (រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ២០២៣-២០២៧ ដែលមានគោលដៅចម្បង គឺ "**កសាងគណនេយ្យភាពសមិទ្ធកម្ម**" ដែលតម្រូវឱ្យមានការទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅកាន់ព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថាថវិកាសមិទ្ធកម្មជាស្នូលរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាមួយគ្នានេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ២០២៣ មានចក្ខុវិស័យចង់ "**ប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាពីប្រព័ន្ធផ្តោតលើធាតុចូល និងមានលក្ខណៈមជ្ឈការទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ**"។

## ១.២. ការថ្លែងបញ្ហា

ចាប់តាំងពីសទស្សវត្សទី៨០ មកម្ល៉េះ ប្រទេសកម្ពុជាបានធ្វើកំណែទម្រង់ឆ្ពោះទៅកាន់សេដ្ឋកិច្ចទីផ្សារ ដោយពុះពារឆ្លងកាត់កំណាត់ផ្លូវច្រើនគន្លាក់ និងឧបសគ្គគ្រប់បែបយ៉ាងរហូតបានឈានមកដល់ចំណុចរបត់ឥតថយក្រោយនៅឆ្នាំ១៩៨៩ ហើយបន្តបោះជំហានទៅមុខដល់ដំណាក់កាលបោះឆ្នោតលើកដំបូងជាសកលឆ្នាំ១៩៩៣ ដែលកម្ពុជាកាន់សេដ្ឋកិច្ចទីផ្សារ និងជាបន្តបន្ទាប់កម្ពុជាបានធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោករហូតចូលជាសមាជិកអាស៊ាន និងចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។ ជាមួយគ្នានេះ កម្ពុជាមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងការគ្រប់គ្រងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងអភិបាលកិច្ចល្អ ដែលមានបញ្ហារួមមាន៖ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចមានកម្រិត ប្រព័ន្ធថវិកានៅមានកម្រិត ប្រព័ន្ធសារពើពន្ធមិនទាន់មានទំនើបភាវូបនីយកម្ម ប្រព័ន្ធគណនេយ្យសាធារណៈនៅមានកម្រិត ពុំទាន់មានប្រព័ន្ធសវនកម្ម សហគ្រាសសាធារណៈមិនទាន់មានឯកជនភាវូបនីយកម្ម និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅមានកម្រិតនៅឡើយ។ បន្ថែមពីនេះ រាជរដ្ឋាភិបាលកម្ពុជា បានរៀបចំយុទ្ធស្រ្តកម្មវិធី និងសកម្មភាពដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមដូចជា ការធានាសុខសន្តិភាព សន្តិសុខសង្គមជាតិ ការធ្វើសមារណកម្មចូលក្របខ័ណ្ឌតំបន់និងអន្តរជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ប្រព័ន្ធតុលាការ និងកំណែទម្រង់សេដ្ឋកិច្ចធានាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងជម្រុញកំណើនប្រកបដោយចីរភាពរយៈពេលវែង។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរហូតដល់ ៤ដំណាក់ គឺ **ដំណាក់កាលទី១៖** ការបង្កើនភាពជឿទុកចិត្តនៃថវិកា **ដំណាក់កាលទី២៖** ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ **ដំណាក់កាលទី៣៖** ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលយោបាយ និង**ដំណាក់កាលទី៤៖** ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម (រាជរដ្ឋាភិបាលកម្ពុជា, ២០០៤)។

បន្ថែមពីនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី១ មានកម្មវិធីកែទម្រង់ចំនួន ៣ផ្នែក រួមមាន៖ ១.សកម្មភាពចាំបាច់សម្រាប់បំពេញក្នុងជំហានទី១ ២.សកម្មភាពការងារសម្រាប់ជំហានបន្ទាប់ដែលត្រូវចាប់ផ្តើម និង ៣.សកម្មភាពការងារអនុវត្តវិធានការកែលម្អរចនា-

សម្ព័ន្ធ ការពង្រឹងសមត្ថភាពស្ថាប័ន និងមានចង្កោមសកម្មភាព ៣៣។ ជាលទ្ធផលកម្ពុជាបានផ្លាស់ប្តូរពីស្ថានភាពខ្វះខាតសាច់ប្រាក់ជំរ៉ាំរ៉ៃ ទៅជាអតិរេកសាច់ប្រាក់ ដោយបានលុបបំបាត់បំណុលកកស្ទះនៅរតនាគារជាតិ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន ការកាត់បន្ថយនីតិវិធីចំណាយ ការពង្រឹងការប្រើប្រាស់ប្រព័ន្ធធនាគារ ការបង្កើតទុនវិនិយោគសាធារណៈលើការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច ពង្រឹងនិងពង្រីកសេវាសាធារណៈ និងដោះស្រាយផលវិបាកដែលកើតពីគ្រោះធម្មជាត់ជាដើម។ ជាមួយគ្នានេះ មានបញ្ហាប្រឈមមួយចំនួននៅដំណាក់កាលទី១ រួមមាន៖ ការយល់ដឹង និងការចូលរួមក្នុងកម្មវិធីកែទម្រង់ពីគ្រប់ភាគីពាក់ព័ន្ធនៅមានកម្រិត ភាពមិនឯកភាពគ្នាលើកម្មវិធីកែទម្រង់ កិច្ចសហការនិងកិច្ចសម្របសម្រួលអន្តរក្រសួងនៅមានកម្រិតនៅឡើយ សមត្ថភាពមន្ត្រីនៅមានកម្រិត និងការលើកទឹកចិត្តនិងភាពម្ចាស់ការនៅមានកម្រិតនៅឡើយ (រាជរដ្ឋា-ភិបាលកម្ពុជា, ២០០៨)។

ទន្ទឹមនឹងនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ មានកម្មវិធីកែទម្រង់ ៣ជំហាន រួមមាន៖ ១.ការអនុវត្តផែនការសកម្មភាពរួម ដែលចែកជា ១៤គោលបំណង និង ៧៣ចង្កោមសកម្មភាព ដែលមានបញ្ហាប្រឈម និងការកែសម្រួមសូចនាករសមិទ្ធកម្មគន្លឹះ ២.យុទ្ធសាស្ត្រ ៣+២ ដើម្បីជំរុញប្រសិទ្ធភាពការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (Financial Management Information System) និង ៣.ការអនុវត្តផែនការសកម្មភាពរួម និងយុទ្ធសាស្ត្រ ៣+២ ដែលមានធ្វើបច្ចុប្បន្នភាព ឬចែកចេញ ៤ផ្នែក ១៤គោលបំណង និង ៦៣ចង្កោមសកម្មភាព។ ជាលទ្ធផលចំណូលក្នុងស្រុកច្បាប់ហិរញ្ញវត្ថុបានអនុម័តកម្រិតលម្អៀង ៥% ដោយទទួលបានលទ្ធផល ១១០,៧% (ជាពិសេសតាមរយៈការកែទម្រង់រដ្ឋបាលគយ និងពន្ធដារ) បំណុលកកស្ទះមិនលើសពី ២% នៃចំណាយសរុប ការទូទាត់អាណាតិរតនាគារជាតិមិនលើសពី ៦០ថ្ងៃនៃថ្ងៃធ្វើការ។ ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ដោយការកែលម្អជាច្រើនលើនីតិវិធី អនុវត្តថវិកា មាតិកាថវិកាថ្មី និងប្លង់គណនេយ្យថ្មី ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត ព្រមទាំងរៀបចំចំណាត់ថ្នាក់ ថវិកា តាមមុខងារ ប្រភពធនធាន និងគម្រោង ត្រូវបានសិក្សានិងរៀបចំត្រៀមដាក់ឱ្យអនុវត្ត។ ជាពិសេស ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ សម្រាប់មុខងារវិភាជន៍ថវិកា (Budget Allocation) និងមុខងារសៀវភៅធំ (General Ledger) នៅក្នុងអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ។ ក្រុមការងារគ្រប់គ្រងគម្រោងព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈក៏បានបញ្ចប់ការរៀបចំកសាងប្រព័ន្ធលើមុខងារទាំង៦ ដែលរួមមាន ការវិភាជវថិកា (Budget allocation) សៀវភៅធំ (General Ledner) ការត្រួតពិនិត្យធានាចំណាយ (Commitment Control) គណនីដែលត្រូវសង (Account Payable) គណនីដែលត្រូវទារ (Account Receivable) និងការគ្រប់គ្រងសាច់ប្រាក់ (Cash Management)។ ជាមួយគ្នានេះ បញ្ហាប្រឈមនៃកម្មវិធីកែទម្រង់ដំណាក់កាលទី២ មានដូចជា៖ ១.ការកំណត់គោលនយោបាយ គោលការណ៍ ឬការផ្តល់ទិសដៅនៅមានកម្រិត ២.ការរៀបចំ ការអនុវត្ត និងការតាមដានត្រួតពិនិត្យនៅមានកម្រិត ៣.ក្រសួង-ស្ថាប័នការយល់ដឹងពីមុខងារភារកិច្ច និងសកម្មភាពរបស់ខ្លួនមិនទាន់ច្បាស់ ឬខ្វះជំនាញប្រតិបត្តិ និង ៤.កិច្ចសហការ និងកិច្ចសម្របសម្រួលផ្ទៃក្នុងក្រសួង-ស្ថាប័ននៅមានកម្រិតខ្លាំងនៅឡើយ (រាជរដ្ឋាភិបាលកម្ពុជា, ២០១៦)។

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមកន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានបន្តដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦។ កម្មវិធីកែទម្រង់នេះ មានផែនការសកម្មភាពចែកចេញជា ៥ផ្នែក ២១គោលបំណង និង ៦៧ចង្កោមសកម្មភាព ក្នុងនេះផែនការសកម្មភាពទាំង ៥ផ្នែក រួមមាន៖ **១**.ភាពជឿទុកចិត្តបាននៃថវិកា **២**.គណនេយ្យភាពហិរញ្ញវត្ថុ **៣**.ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ **៤**.ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ និង **៥**.ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព។ ជាលទ្ធផលកម្មវិធីកែទម្រង់ដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" គឺបានចាប់ផ្ដើមផ្លាស់ប្ដូរប្រព័ន្ធថវិកាបច្ចុប្បន្ន ព្រមទាំងការចាប់ផ្ដើម ពង្រឹង និងពង្រីកការសាកល្បងប្រព័ន្ធថវិកាកម្មវិធីជាជំហានៗ ទៅក្នុងចំណោមក្រសួង ស្ថាប័ន និងរដ្ឋបាល រាជធានី ខេត្ត។ ក្នុងដំណាក់កាលនេះ រាជរដ្ឋាភិបាលដាក់ចេញយុទ្ធសាស្ត្រគន្លឹះៗ រួមមាន៖ **១**.យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥ **២**.យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥ **៣**.យុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩-២០២៥ **៤**.យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥ **៥**.យុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និង **៦**.ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥ ដែលភ្ជាប់ជាមួយនឹងផែនការសកម្មភាពលម្អិត ដើម្បីធានាថាគ្រប់អង្គភាពពាក់ព័ន្ធ ទាំងអសចូលរួមអនុវត្តប្រកបដោយឆន្ទៈ មនសិការ និងការទទួលខុសត្រូវខ្ពស់។ ជាមួយគ្នានេះ ច្បាប់គន្លឹះៗ មួយចំនួនត្រូវបានប្រកាសដាក់ឱ្យអនុវត្ត ដើម្បីពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ក្នុងនោះ រួមមាន៖ច្បាប់ស្ដីពីការគ្រប់គ្រងល្បែងពាណិជ្ជកម្ម ច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ច្បាប់ស្ដីពីមូលបត្ររដ្ឋ ច្បាប់ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងច្បាប់ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។ ជាមួយគ្នានេះ កម្មវិធីកែទម្រង់ដំណាក់កាលទី៣ មានបញ្ហាប្រឈមមួយចំនួន កម្រិតដឹកនាំ កម្រិតបច្ចេកទេស និងជាពិសេសវិបត្តិសកលរួមមានជំងឺកូវីដ-១៩ និងវិបត្តិសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ដែលមានផលប៉ះពាល់ជាអវិជ្ជមានដល់សង្គម និងសេដ្ឋកិច្ចកម្ពុជា និងកិច្ចដំណើរការកម្មវិធីកែទម្រង់ (រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

ជាមួយគ្នានេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ឱ្យអនុវត្តចក្ខុវិស័យនិងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ២០២៣-២០២៧ ដែលមានគោលដៅចម្បង គឺ "**កសាងគណនេយ្យភាពសមិទ្ធកម្ម**" ដែលតម្រូវឱ្យមានការទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅកាន់ព័ត៌មានសមិទ្ធកម្ម ឬហៅកាត់ថាថវិកាសមិទ្ធកម្មជាស្នូលរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ កម្មវិធីកែទម្រង់នេះ ក៏បានដាក់ផែនការសកម្មភាពរួមដំណាក់កាលទី៤ មានចំនួន ៤ ផ្នែក រួមមាន៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យភាពសមិទ្ធកម្ម និងការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត។

## ១.៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ក្នុងគោលបំណងស្វែងយល់អំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ភាគីជាប់ពាក់ព័ន្ធ ព្រមទាំងសារៈសំខាន់របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការផ្ដល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជា ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីធានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលធ្វើឱ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។ បន្ថែមពីនេះ ការសិក្សាស្រាវជ្រាវនេះ នឹងរៀបចំផ្ដល់ជាមតិយោបល់ ឬអនុសាសន៍ទៅលើភាពខ្វះចន្លោះនៃកម្មវិធីឱ្យបានល្អប្រសើរឡើង។

## ១.៤ សំណួរនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងវត្ថុបំណងនៃការសិក្សានេះ មានគោលបំណងឆ្លើយសំណួរស្រាវជ្រាវដូចខាងក្រោម៖

១.តើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអ្វី?

២.តើស្ថាប័នណាខ្លះទទួលបន្ទុកការងារដឹកនាំ អនុវត្ត និងសម្របសម្រួលកម្មវិធីកែទម្រង់នេះរហូតដល់ទទួលបានភាពជោគជ័យបច្ចុប្បន្ន និងបន្តនៅអនាគត?

៣.តើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានឥទ្ធិពលវិជ្ជមាន ឬអវិជ្ជមានអ្វីខ្លះដល់ស្ថាប័នសាធារណៈ និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋកម្ពុជា?

## ១.៥. កម្មវត្ថុនៃការសិក្សាស្រាវជ្រាវ

កម្មវត្ថុចម្បង នៅក្នុងការសិក្សាស្រាវជ្រាវពាក់ព័ន្ធទៅនឹងប្រធានបទនេះរួមមាន៖

- សិក្សាលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទី និងភារកិច្ច
- សិក្សាអំពីស្នូលសំខាន់ៗរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សិក្សាអំពីស្ថាប័ន និងភាគីពាក់ព័ន្ធទទួលបន្ទុកការងារដឹកនាំ អនុវត្ត និងសម្របសម្រួលកម្មវិធីកែទម្រង់នេះ
- សិក្សាអំពីឥទ្ធិពលរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចំពោះស្ថាប័នសាធារណៈ និងការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋកម្ពុជា។

## ១.៦. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ជារួមមក ការស្រាវជ្រាវនេះនឹងផ្ដល់អត្ថប្រយោជន៍ជាច្រើន ដូចរៀបរាប់ខាងក្រោមនេះ៖

**ចំពោះខ្ញុំបាទ**

- ផ្ដល់ជាចំណេះដឹងឱ្យកាន់តែស៊ីជម្រៅទៅលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្សារភ្ជាប់ជាមួយនឹង ទ្រឹស្ដីដែលបានរៀនកន្លងមក។
- ស្វែងយល់អំពីស្នូលសំខាន់ៗរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទី និងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ

- ស្វែងយល់អំពីស្នូលសំខាន់ៗរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ស្វែងយល់អំពីឥទ្ធិពលរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានផលប៉ះពាល់ដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា
- ស្វែងយល់អំពីឥទ្ធិពលរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានផលប៉ះពាល់ដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋកម្ពុជា។

**ចំពោះនិស្សិត និងអ្នកស្រាវជ្រាវ**

- ជាទុនមួយសម្រាប់និស្សិត និងអ្នកស្រាវជ្រាវទាំងអស់ដែលមានចំណាប់អារម្មណ៍លើប្រធានបទនេះ ឱ្យស្វែងយល់បន្ថែម។
- រំលឹកឡើងវិញនូវទ្រឹស្តីដែលបានយល់ដឹងកន្លងមក។
- ផ្តល់ជាចំណេះដឹង ឱ្យកាន់តែស៊ីជម្រៅទៅលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្សារភ្ជាប់ជាមួយនឹង ទ្រឹស្តីដែលបានរៀនកន្លងមក។
- ស្វែងយល់អំពីស្នូលសំខាន់ៗរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទី និងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ
- ស្វែងយល់អំពីស្នូលសំខាន់ៗរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ស្វែងយល់អំពីឥទ្ធិពលរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានផលប៉ះពាល់ដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា
- ស្វែងយល់អំពីឥទ្ធិពលរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានផលប៉ះពាល់ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋកម្ពុជា។

**ចំពោះមជ្ឈដ្ឋានទូទៅ**

- ដើរតួជាព័ត៌មាន និងឯកសារដល់សាធារណជនដែលមានបំណងចង់ដឹងអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ស្វែងយល់អំពីស្នូលសំខាន់ៗរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទី និងភារកិច្ចរបស់ស្ថាប័នពាក់ព័ន្ធ
- ស្វែងយល់អំពីស្នូលសំខាន់ៗរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ស្វែងយល់អំពីឥទ្ធិពលរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានផលប៉ះពាល់ដល់ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា
- ស្វែងយល់អំពីឥទ្ធិពលរបស់កម្មវិធីទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានផលប៉ះពាល់ដល់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋកម្ពុជា។

## ១.៧. វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ដោយពិនិត្យឃើញវិសាលភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈទូលំទូលាយក្នុងការសិក្សាស្រាវជ្រាវឱ្យបានលម្អិត និងស៊ីជម្រៅទើបខ្ញុំសិក្សាស្រាវជ្រាវលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទី និងភារកិច្ចរបស់កម្មវិធី

និងភាគីពាក់ព័ន្ធ ព្រមទាំងឥទ្ធិពលរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចំពោះប្រជាពលរដ្ឋកម្ពុជា និងក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មកធ្វើសិក្សាស្រាវជ្រាវ និងរៀបចំសរសេរនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញរដ្ឋបាលសាធារណៈក្រោមប្រធានបទ "**ឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា**" ដោយផ្តោតលើអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការសិក្សាស្រាវជ្រាវនេះផ្តោតលើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តួនាទី និងភារកិច្ចរបស់កម្មវិធី និងភាគីពាក់ព័ន្ធ ព្រមទាំងឥទ្ធិពលរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈចំពោះប្រជាពលរដ្ឋកម្ពុជា និងក្រសួង-ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

ដែនកំណត់នៃការសិក្សាស្រាវជ្រាវ គឺប្រមូលទិន្នន័យមានចំនួនពីរប្រភព គឺប្រភពទិន្នន័យបឋម (Primary Data) និងប្រភពនិន្នន័យបន្ទាប់បន្សំ (Secondary Data)។ ប្រភពទិន្នន័យបឋម (Primary Data) គឺជាទិន្នន័យដែលទទួលបានពីការស្ទង់មតិពីមន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈ Google Forms ចំនួន ៥០រូប។

## ១.៨ ប្លង់នៃការសិក្សាស្រាវជ្រាវ

**ជំពូកទី ១៖** គោលបំណងនៃជំពូកនេះគឺជាព័ត៌មានណែនាំរួមមាន សាវតានៃការសិក្សាស្រាវជ្រាវ ការថ្លែងបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ សំណួរនៃការសិក្សាស្រាវជ្រាវ កម្មវត្ថុនៃការសិក្សាស្រាវជ្រាវសំណួរស្រាវជ្រាវ គោលបំណងស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ វិសាលភាពនិងដែនកំណត់នៃការសិក្សាស្រាវជ្រាវ និងប្លង់នៃការសិក្សាស្រាវជ្រាវឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី ២៖** គោលបំណងនៃជំពូកនេះ គឺដើម្បីពិនិត្យឡើងវិញនូវទ្រឹស្តីដែលទាក់ទងនឹងប្រធានបទ នៃការសិក្សាស្រាវជ្រាវ។ នៅក្នុងជំពូកនេះ ត្រូវបានបែងចែកជាប្រាំផ្នែក រួមមាន សេចក្តីផ្តើមចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក្យគន្លឹះ ទិដ្ឋភាពទូទៅនៃការដាក់ចេញកម្មវិធីកែទម្រង់ ផែនការសកម្មភាពរួម និងក្របខ័ណ្ឌលទ្ធផលដំណាក់កាលទី៤ ការសិក្សាសម្មតិកម្ម និងការរំលឹកវិធីសាស្ត្រស្រាវជ្រាវ។ នៅក្នុងទ្រឹស្តីនេះ គឺមានលក្ខណៈជាក់ស្តែង ទ្រឹស្តីបែបគោលគំនិត និងទ្រឹស្តីបែបពិសោធន៍ការសិក្សាផ្តោតលើសក្តានុពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ជំពូកទី ៣៖** គោលបំណងនៃជំពូកនេះគឺដើម្បីបង្ហាញអំពីទិដ្ឋភាពទូទៅរចនាសម្ព័ន្ធ និងយន្តការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងសមត្ថភាពស្ថាប័ន។

**ជំពូកទី ៤៖** គោលបំណងនៃជំពូកនេះគឺដើម្បីពន្យល់ពីវិធីសាស្ត្រដែលត្រូវបានប្រើក្នុងការសិក្សាបច្ចុប្បន្ន។ សម្រាប់គោលបំណងនៃជំពូកនេះត្រូវបានចែកជា ៦ ផ្នែក។ ផ្នែកទី១ ការកំណត់ទំហំសំណាក និងបច្ចេកទេសជ្រើសរើសសំណាក ផ្នែកទី២ ប្រភេទ និងប្រភពទិន្នន័យ ផ្នែកទី៣ ឧបករណ៍

ក្នុងការវិភាគទិន្នន័យ ផ្នែកទី៤ នីតិវិធីនៃការប្រមូលទិន្នន័យ នៅផ្នែកទី៥ បរិយាយ និងការគណនាពីភាពទុកចិត្តនៃកម្រងសំណួរ និងផ្នែក៦ ចុងក្រោយ ជាសេចក្ដីសន្និដ្ឋាន។

**ជំពូកទី ៥៖** គោលបំណងនៃជំពូកនេះ គឺដើម្បីធ្វើការវិភាគទៅលើទិន្នន័យដែលបានប្រមូលពីប្រជាពលរដ្ឋ ដែលរស់នៅក្នុងខណ្ឌទួលគោក។ ដោយជំពូកនេះ ត្រូវបានបែងចែកជា ៣ ផ្នែកសំខាន់ៗ រួមមាន ផ្នែកទី១ វិភាគ អំពីអត្តសញ្ញាណអ្នកឆ្លើយតប, ផ្នែកទី២ វិភាគពីមធ្យមមេគុណដើម្បីកំណត់រកភាពលម្អៀងនៃរង្វាស់វិភាគតាម Regression ដើម្បីកំណត់ទំនាក់ទំនងរបស់អថេរមិនឯករាជ្យ និងអថេរឯករាជ្យ និងចុងក្រោយជាការបកស្រាយ លទ្ធផល។

**ជំពូកទី ៦៖** ជំពូកនេះនឹងផ្ដោតទៅលើការសង្ខេបដើម្បីកំណត់នូវចំណុចសំខាន់ៗនៃការផ្ដល់សេវាសាធារណៈ នៅក្នុងការិយាល័យច្រកចេញចូលតែមួយ និងការបង្ហាញពីផលប៉ះពាល់នៃការអនុវត្តការងាររបស់មន្ត្រី ដើម្បីការស្រាវជ្រាវ និងការសន្និដ្ឋាន។ ជំពូកដដែលនេះ ត្រូវបានបែងចែកជា ៣ ផ្នែកតូចៗ ដូចជា៖ ផ្នែកទី១ ការសង្ខេបអំពីលទ្ធផល ផ្នែកទី២ សេចក្ដីសន្និដ្ឋាន និងអនុសាសន៍ និងផ្នែកទី៣ ការស្រាវជ្រាវអនាគត។

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១. សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះ គឺដើម្បីពិនិត្យឡើងវិញនូវទ្រឹស្តីដែលទាក់ទងនឹងប្រធានបទនៃការសិក្សាស្រាវជ្រាវ។ នៅក្នុងជំពូកនេះ ត្រូវបានបែងចែកជាបីផ្នែករួមមាន ការរំលឹកទ្រឹស្តី ក្របខ័ណ្ឌការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពាក្យគន្លឹះ។ នៅក្នុងទ្រឹស្តីនេះ គឺមានលក្ខណៈជាក់ស្តែង ទ្រឹស្តីបែបគោលគំនិត និងទ្រឹស្តីបែបពិសោធន៍ការសិក្សាផ្តោតលើឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។ ចុងបញ្ចប់នៃជំពូកនេះ ការសន្និដ្ឋានត្រូវបានផ្តល់ឱ្យក្នុងសង្ខេបឡើងវិញ។

## ២.២.ការរំលឹកទ្រឹស្តី

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកម្មវិធីមួយមានសារៈសំខាន់សម្រាប់ការធានាការប្រើប្រាស់ធនធានសាធារណៈប្រកបដោយប្រសិទ្ធភាពក្នុងការសម្រេចបាននូវគោលបំណងគោលនយោបាយ និងការរក្សានូវទំនុកចិត្តសាធារណៈ។ ស្នូលរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន៖ ការពង្រឹងភាពជឿជាក់នៃថវិកា ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ការភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យភាពសមិទ្ធកម្ម និងការគាំទ្រកម្មវិធីកំណែទម្រង់ប្រកបដោយនិរន្តរភាព។

### ២.២.១.ភាពជឿជាក់នៃថវិកា

ភាពជឿជាក់នៃថវិកា គឺជាការកំណត់វិសាលភាពរបស់រដ្ឋាភិបាលក្នុងការអនុវត្តថវិការតាមការគ្រោងទុក ព្រមទាំងជាមូលដ្ឋានគ្រឹះសម្រាប់អភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព។ ទន្ទឹមនឹងនេះ ថវិកាដែលអាចជឿទុកចិត្តបានធានាថាតើធនធានត្រូវបានបែងចែកទៅស្របតាមអាទិភាពនៃចំណាយ ការកាត់បន្ថយឱនភាពសារពើពន្ធ និងការកែលម្អការផ្តល់សេវាសាធារណៈ (Cangiano et al., 2013)។ ជាមួយគ្នានេះ ការកង្វះភាពជឿជាក់លើថវិកាអាចនាំឱ្យមានការចំណាយមានភាពមិនត្រឹមត្រូវ ភាពគ្មានប្រសិទ្ធភាព និងការបាត់បង់ទំនុកចិត្តពីសាធារណជន (World Bank, 2013)។ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រដ្ឋាភិបាលកំពុងអនុម័តវិធានការដូចជា ការពង្រឹងការព្យាករណ៍ប្រាក់ចំណូល ពង្រឹងការគ្រប់គ្រងការចំណាយ និងការបង្កើនតម្លាភាពក្នុងដំណើរការថវិកា។ តាមរយៈការសិក្សាដោយ Andrews et al.(2014) គូសបញ្ជាក់ពីសារៈសំខាន់នៃក្របខ័ណ្ឌសារពើពន្ធរយៈពេលមធ្យម និងប្រព័ន្ធតាមដានការចំណាយក្នុងការធ្វើអោយប្រសើរឡើងនូវភាពជឿជាក់នៃថវិកា។ លើសពីនេះ ការប្រើប្រាស់ឧបករណ៍ឌីជីថល និងស្វ័យប្រវត្តិកម្មក្នុងការរៀបចំថវិកា និងការអនុវត្តត្រូវបានបង្ហាញថាបង្កើនគណនេយ្យភាព និងកាត់បន្ថយនូវចំណាយគ្មាប្រយោជន៍ (Schick, 1998)។

### ២.២.២.គណនេយ្យភាពហិរញ្ញវត្ថុ

គណនេយ្យភាពហិរញ្ញវត្ថុ គឺធានាថាធនធានសាធារណៈត្រូវបានគ្រប់គ្រងប្រកបដោយការទទួលខុសត្រូវ និងតម្លាភាព តាមរយៈការមានប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាព រួមទាំងសវនកម្មផ្ទៃក្នុង

សវនកម្មខាងក្រៅ និងការរាយការណ៍ប្រកបដោយតម្លាភាព។ នៅក្នុងក្របខ័ណ្ឌគណនេយ្យភាព គឺចាំបាច់ដើម្បីកាត់បន្ថយអំពើពុករលួយ និងភាពគ្មានប្រសិទ្ធភាពដែលរារាំងដល់កិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ (Cangiano et al., 2013)។ លើសពីនេះ តួនាទីរបស់ស្ថាប័នសវនកម្មកំពូល (SAIs) គឺជាការលើកកម្ពស់គណនេយ្យភាពហិរញ្ញវត្ថុតាមរយៈការវាយតម្លៃឯករាជ្យនៃការចំណាយរបស់រដ្ឋាភិបាល ដោយធានានូវការអនុលោមតាមស្តង់ដារច្បាប់ និងបទប្បញ្ញត្តិ។ ជាមួយគ្នានេះ ការអនុម័តស្តង់ដាគណនេយ្យវិស័យសាធារណៈអន្តរជាតិ (IPSAS) គឺជាឧបករណ៍មួយក្នុងការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃរបាយការណ៍ហិរញ្ញវត្ថុក្នុងវិស័យសាធារណៈ ដែលអនុញ្ញាតឱ្យរដ្ឋាភិបាលបង្ហាញទិដ្ឋភាពពិត និងយុត្តិធម៌នៃប្រតិបត្តិការហិរញ្ញវត្ថុរបស់ពួកគេ (World Bank, 2013)។ ជាងនេះទៅទៀត ការអនុវត្តថវិកាដែលមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងការរៀបចំថវិកា និងការត្រួតពិនិត្យជាយន្តការដ៏មានប្រសិទ្ធភាពក្នុងការពង្រឹងគណនេយ្យភាព និងជំរុញការជឿទុកចិត្តរវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ (Andrew et al., 2017)។

### ២.២.៣.ការភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ការភ្ជាប់ថវិកាទៅនឹងគោលនយោបាយ មានសារៈសំខាន់សម្រាប់ការតម្រឹមធនធានហិរញ្ញវត្ថុជាមួយនឹងគោលដៅអភិវឌ្ឍន៍។ ការអនុវត្តថវិកាផ្អែកលើសមិទ្ធកម្ម និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម បានលេចចេញជាឧបករណ៍មានប្រសិទ្ធភាពសម្រាប់អនុវត្តថវិការបស់ខ្លួន (Allen & Tommasi, 2001)។ តាមរយៈការភ្ជាប់ថវិកាទៅនឹងគោលនយោបាយ រដ្ឋាភិបាលអាចផ្តល់អាទិភាពលើការចំណាយដែលផ្តល់ផលចំណេញសង្គម និងសេដ្ឋកិច្ចខ្ពស់បំផុត។ ឧទាហរណ៍ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម បានផ្តល់នូវទស្សនវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា ដោយធានាថាធនធានត្រូវបានបែងចែកសមស្របតាមវិស័យអាទិភាព និងការរក្សាបាននូវចំណូលសារពើពន្ធ។ ម៉្យាងវិញទៀត ការរៀបចំថវិកាផ្អែកលើសមិទ្ធកម្ម ផ្តោតលើលទ្ធផលជាងធាតុចូល ដោយធានាថាកម្មវិធីរដ្ឋាភិបាលផ្តល់លទ្ធផលជាក់ស្តែង។ យោងតាម Schick (1998) ការអនុវត្តប្រកបដោយជោគជ័យ តម្រូវឱ្យមានសមត្ថភាពស្ថាប័នរឹងមាំ ការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមភាគីពាក់ព័ន្ធ ព្រមទាំងការតាមដាន និងការវាយតម្លៃជាបន្តបន្ទាប់។

### ២.២.៤.គណនេយ្យភាពសមិទ្ធកម្ម

គណនេយ្យសមិទ្ធកម្ម គឺជាការកំណត់គោលដៅជាក់លាក់ អាចវាស់វែងបាន ការតាមដានវឌ្ឍនភាព និងការអនុវត្តមន្ត្រីសាធារណៈប្រកបដោយការទទួលខុសត្រូវ និងទទួលបានលទ្ធផល។ ជាមួយគ្នានេះ គណនេយ្យភាពសមិទ្ធកម្ម ត្រូវបានទទួលស្គាល់ជាធាតុផ្សំសំខាន់នៃអភិបាលកិច្ចប្រកបដោយប្រសិទ្ធភាព (Bovens et al., 2008)។ ជាមួយគ្នានេះ ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃសមិទ្ធកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជំរុញគណនេយ្យភាពសមិទ្ធកម្ម តាមរយៈការប្រមូល និងវិភាគទិន្នន័យលើសូចនាករការអនុវត្តសំខាន់ៗ (KPIs) របស់រដ្ឋាភិបាល ដែលអាចវាយតម្លៃផលប៉ះពាល់នៃកម្មវិធី និងសម្រេចចិត្តសម្រាប់ការអន្តរាគមន៍នាពេលអនាគត។ បន្ថែមពីនេះ ការចេញផ្សាយរបាយការណ៍លទ្ធផលការងារជាសាធារណៈ ជួយបង្កើននូវតម្លាភាព និងរដ្ឋាភិបាលទទួលខុសត្រូវចំពោះប្រជាពលរដ្ឋផងដែរ (Andrew et al., 2017)។ ក្រៅពីនេះ យន្តការគណនេយ្យភាពមានសារៈសំខាន់ជាពិសេសក្នុងការបង្កើតជឿទុកចិត្តសាធារណៈ ដោយការបម្រើប្រាស់មធ្យោបាយក្នុងការកសាងទំនុកចិត្តដោយ

បង្ហាញពីការប្តេជ្ញាចិត្តអនុវត្តប្រកបដោយតម្លាភាព យុត្តិធម៌ និងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ។

### ២.២.៥.កម្មវិធីកំណែទម្រង់ប្រកបដោយនិរន្តរភាព

កម្មវិធីកំណែទម្រង់ប្រកបដោយនិរន្តរភាពមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរយៈពេលវែង។ កម្មវិធីទាំងនេះត្រូវតែមានភាពស៊ីសង្វាក់គ្នាជាមួយនឹងរបៀបវារៈកំណែទម្រង់ទូលំទូលាយ ដូចជាកំណែទម្រង់រដ្ឋបាលសាធារណៈ វិមជ្ឈការ និងគំនិតផ្តួចផ្តើមប្រឆាំងអំពើពុករលួយ (World Bank, 2013)។ នេះបើយោងតាមលោក Andrews et al. (2017) កំណែទម្រង់ប្រកបដោយនិរន្តរភាព គឺជាការសម្របសម្រួល ការដោះស្រាយ និងការវិវត្តក្នុងការឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកំពុងកើតមាន។ លើសពីនេះ កត្តាសំខាន់ៗដែលរួមចំណែកដល់និរន្តរភាពនៃកម្មវិធីកំណែទម្រង់ដូចជាការប្តេជ្ញាចិត្តផ្នែកនយោបាយ ការចូលរួមពីភាគីពាក់ព័ន្ធ និងការកសាងសមត្ថភាព។ លើសពីនេះ ការធានាបាននូវភាពស៊ីសង្វាក់គ្នាក្នុងចំណោមគំនិតផ្តួចផ្តើមកំណែទម្រង់ផ្សេងៗ ដើម្បីបង្កើនការរួបរួមសហការគ្នា។ ឧទាហរណ៍ ការរួមបញ្ចូលកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងគោលនយោបាយតាមវិស័យ ដូចជាសុខភាព និងការអប់រំ អាចពង្រីកឥទ្ធិពលរបស់ពួកគេទៅលើការផ្តល់សេវា និងការកាត់បន្ថយភាពក្រីក្រ (Cangiano et al., 2013)។ ភាពជោគជ័យនៃកម្មវិធីកំណែទម្រង់ប្រកបដោយនិរន្តរភាព អាស្រ័យលើការបង្កើតក្របខ័ណ្ឌស្ថាប័នដ៏រឹងមាំដែលគាំទ្រដល់គណនេយ្យភាព តម្លាភាព និងការចូលរួម។ ក្របខ័ណ្ឌទាំងនេះ ត្រូវតែបំពេញនូវបង្កើតវប្បធម៌ប្រកបដោយក្រមសីលធម៌ និងអភិបាលកិច្ចល្អ ដើម្បីធានាបាននូវសុចរិតភាព និងភាពជន់នៃកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់។

## ២.៣.ក្របខ័ណ្ឌការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ២.៣.១. ចក្ខុវិស័យ

ចក្ខុវិស័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានកំណត់តាំងពីដំណាក់កាលទី១ នៅតែរក្សាបានភាពត្រឹមត្រូវសម្រាប់ដំណាក់កាលទី៤ ពោលគឺ “**ការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ដោយផ្លាស់ប្តូរពីប្រព័ន្ធដែលផ្តោតលើធាតុចូលនិងមានលក្ខណៈមជ្ឈការទៅកាន់ប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការ ស្របតាមស្តង់ដានិងឧត្តមានុវត្តន៍អន្តរជាតិ**”។ បន្ថែមពីនេះ ចក្ខុវិស័យវិធីកែទម្រង់នេះ នឹងធ្វើឱ្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាកាន់តែមានភាពរឹងមាំ និងឈានទៅសម្រេចបានលទ្ធផលចុងក្រោយទាំង ៣ គឺ បូរណភាពនៃការគោរពវិន័យថវិកា ប្រសិទ្ធភាពនៃថវិកា (ទាំងក្នុងផ្នែកវិភាជន៍និងក្នុងផ្នែកប្រតិបត្តិការ) និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៣)។

### ២.៣.២.យុទ្ធសាស្ត្រនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ដើម្បីសម្រេចចក្ខុវិស័យរបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកតាំងពីចុងឆ្នាំ២០០៤ រហូតមកនូវ “អភិក្រមជាខឿននិងជាដំណាក់កាល (Platform Approach)” ជាយុទ្ធសាស្ត្រកែទម្រង់ដែលជាអភិក្រមមានលក្ខណៈពិសេស ៣យ៉ាង គឺ

៖ ១.ការកែទម្រង់ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ ត្រូវមានគោលបំណងស្នូលច្បាស់លាស់ ដែលឆ្លើយតបទៅនឹងចក្ខុវិស័យនៃកម្មវិធីកែទម្រង់ ២.ការកែទម្រង់ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗត្រូវជាមូលដ្ឋានសម្រាប់ការកែទម្រង់ក្នុងខឿនបន្តបន្ទាប់ និង ៣.សមិទ្ធផលផ្សេងៗដែលសម្រេចបានក្នុងខឿនមុនៗ ឬដំណាក់កាលមុនៗ ត្រូវបន្តពង្រឹងបន្ថែមក្នុងខឿន ឬដំណាក់កាលបន្តបន្ទាប់។

ស្របតាមអភិក្រមនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ត្រូវបានរៀបចំឡើងដោយបែងចែកជា ៤ ខឿន និង ៤ ដំណាក់កាល។ លើសពីនេះ ការកែទម្រង់ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ បានឆ្លុះបញ្ចាំងតាមរយៈផែនការសកម្មភាពរួមមួយ (CAP) ដោយអង្គភាព ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ ត្រូវរៀបចំផែនការសកម្មភាពលម្អិតរបស់ខ្លួន ដោយផ្អែកលើផែនការសកម្មភាពរួម។ ការកែទម្រង់ ក្នុងខឿននីមួយៗ ឬដំណាក់កាលនីមួយៗ មានគោលបំណង និងសម្រេចសមិទ្ធផលដូចខាងក្រោម៖

- **ដំណាក់កាលទី១ "ការកសាងភាពជឿទុកចិត្តនៃថវិកា"** ៖ ការកែទម្រង់នៅក្នុងដំណាក់កាលទី១ ចំណាយអស់រយៈពេលប្រហែល៤ឆ្នាំ គិតចាប់ពីចុងឆ្នាំ២០០៤ រហូតដល់ឆ្នាំ ២០០៨ ដោយសម្រេចបានជោគជ័យនូវមូលដ្ឋានគ្រឹះនៃការពង្រឹងការប្រមូលចំណូល ការគ្រប់គ្រងចំណូល ការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អចំណាយ។
- **ដំណាក់កាលទី២ "ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ"**៖ ការកែទម្រង់នៅក្នុងដំណាក់កាលទី២ ចំណាយអស់រយៈពេលប្រហែល ៧ឆ្នាំ ពិតចាប់ពីដើមឆ្នាំ២០០៩ រហូតដល់ឆ្នាំ ២០១៥ ដោយ សម្រេចបាននូវមូលដ្ឋានគ្រឹះសំខាន់ៗ សម្រាប់ការកសាងគណនេយ្យភាពហិរញ្ញវត្ថុរួមមាន ការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី មាតិកាថវិកាថ្មី ថវិកាកម្មវិធី ផែនការយុទ្ធសាស្ត្រថវិកា (Budget Strategic Plan) អង្គភាពថវិកា និងប្រព័ន្ធបច្ចេកវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS)។
- **ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** ៖ ការកែទម្រង់នៅក្នុងដំណាក់កាលទី៣ ចំណាយអស់រយៈពេលប្រហែល ៧ឆ្នាំ គិតចាប់ពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០២២ ដោយសម្រេចបាននូវមូលដ្ឋានគ្រឹះសំខាន់ៗ ដូចជាការដាក់ឱ្យអនុវត្តជាផ្លូវការនូវការកែទម្រង់ថ្មីនៃប្រព័ន្ធ FMIS និងការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័ន និងនៅតាមបណ្តារដ្ឋបាលរាជធានី ខេត្តទាំង២៥។
- **ដំណាក់កាលទី៤ "កសាងគណនេយ្យភាពសមិទ្ធកម្ម"**៖ ការកែទម្រង់នៅក្នុងដំណាក់កាលទី៤ ចាប់ផ្តើមពីឆ្នាំ២០២៣ នេះតទៅ។ ដើម្បីសម្រេចឱ្យបាននូវគោលបំណងនេះ ការកែទម្រង់ប្រព័ន្ធថវិកាឆ្ពោះទៅរកប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ឬហៅការថាថវិកាសមិទ្ធកម្ម ត្រូវបានកំណត់ថាជាស្នូល របស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បន្ថែមពីនេះ រាជរដ្ឋាភិបាលបានគិតគូរម៉ត់ចត់ដោយរៀបចំជារចនាសម្ព័ន្ធទ្រទ្រង់ចំនួន ៥ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដូចខាងក្រោម៖

- **ទីមួយ យន្តការស្ថាប័ន៖** នៅដំណាក់កាលទី១ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រមូលផ្តុំនៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ប៉ុន្តែសម្រាប់ដំណាក់កាលទី២ និងដំណាក់កាលបន្តបន្ទាប់ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានលក្ខណៈស្មុកស្មាញនឹងមានវិសាលភាពដល់ក្រសួង ស្ថាប័ន និង រដ្ឋបាលរាជធានីខេត្ត។ ទន្ទឹមនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានភាពប្រទាក់ក្រឡាគ្នាជាមួយកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាល ជាពិសេសគឺ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ហេតុនេះ ការបែងចែកភារកិច្ចរបស់តួអង្គនីមួយៗឱ្យបានច្បាស់លាស់ នៅក្នុងការដ្ឋានកែទម្រង់ និងការចូលរួមយ៉ាងសកម្មពីគ្រប់តួអង្គពាក់ព័ន្ធពិតជាមានសារៈសំខាន់។ ក្នុងន័យនេះ យន្តការស្ថាប័នសម្រាប់អនុវត្តកម្មវិធីកែទម្រង់នេះ មានលក្ខណៈបត់បែន ដែលតម្រូវឱ្យមានការពង្រឹងពង្រីក និងកែលម្អជាប្រចាំស្របតាមបរិការណ៍កែទម្រង់ក្នុងដំណាកកាលនីមួយៗ។
- **ទីពីរ សមត្ថភាពស្ថាប័ន៖** សមត្ថភាពស្ថាប័នត្រូវឆ្លើយតបទៅនឹងគោលបំណងនៃការងារកែទម្រង់ នៅក្នុងដំណាក់កាលនីមួយៗ។ ក្នុងន័យនេះ ផែនការកសាងសមត្ថភាពចាំបាច់ត្រូវរៀបចំសម្រាប់ដំណាក់កាលនីមួយៗ ហើយការងារនេះទាមទារឱ្យមានការកំណត់នឹងវិភាគពិតម្រូវការជំនាញមូលដ្ឋាននិងជំនាញបច្ចេកទេសឱ្យបានច្បាស់លាស់។ ផែនការកសាងសមត្ថភាពនេះ ក៏នឹងក្លាយជាមធ្យោបាយមួយ ក្នុងការចូលរួមចំណែកលើកទឹកចិត្តនិងពង្រឹងភាពជាអ្នកទឹកនាំដល់មន្ត្រី ដែលចូលរួមដោយផ្ទាល់និងប្រយោលក្នុងការងារកែទម្រង់ផងដែរ។
- **ទីបី ធនធានហិរញ្ញវត្ថុ៖** កិច្ចដំណើរការកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុង ដំណាក់កាលនីមួយៗទាមទារឱ្យមានធនធានហិរញ្ញវត្ថុសមស្រប។ កម្មវិធីកែទម្រង់ត្រូវបានគាំទ្រដោយមូលនិធីមួយដែលមានថវិការបស់រាជរដ្ឋាភិបាលនិងហិរញ្ញប្បទានគាំទ្រពីដៃគូអភិវឌ្ឍន៍។
- **ទីបួន វិធានការដោះស្រាយបញ្ហាប្រឈម៖** ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងដំណាក់កាលនីមួយៗទាមទារឱ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះបញ្ហាប្រឈមនានា ដែលបានកើតឡើង និងអាចកើតមានឡើងជាយថាហេតុ។ ក្នុងន័យនេះ វិធានការដោះស្រាយបញ្ហាប្រឈមចាំបាច់ត្រូវបានកំណត់ឱ្យបានច្បាស់លាស់ ដើម្បីធានាបាននូវចលនការនៃការងារកែទម្រង់នេះនៅក្នុងដំណាក់កាលនីមួយៗ។
- **ទីប្រាំ វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ៖** ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលនីមួយៗ ឆ្លុះបញ្ចាំងតាមរយៈផែនការសកម្មភាពរួម និងផែនការសកម្មភាពលម្អិតរបស់អង្គភាពដែលចូលរួមអនុវត្ត។ ផែនការសកម្មភាពលម្អិតរបស់អង្គភាពនីមួយៗ បង្ហាញពីសកម្មភាពដែលត្រូវអនុវត្ត សូចនាករសមិទ្ធកម្មគន្លឹះ និងក្របខ័ណ្ឌពេលវេលា។ ដូចនេះ ដើម្បីធានាបានថាការកែទម្រង់ប្រព្រឹត្តទៅតាម

អ្វីដែលបានកំណត់នៅក្នុងផែនការសកម្មភាពលម្អិត និងដើម្បីធានាថាផែនការសកម្មភាពលម្អិតឆ្លើយតបទៅនឹងបរិការណ៍ជាក់ស្តែងនិងតម្រូវការនៃការកែទម្រង់ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំគឺជាការចាំបាច់។ ក្នុងដំណាក់កាលទី១និងដំណាក់កាលទី២ យន្តការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការងារកែទម្រង់មានលក្ខណៈបត់បែនដោយតម្រូវតាមបរិការណ៍ជាកន្លែងនៃការកែទម្រង់។ ឆ្លងកាត់បទពិសោធន៍នៃការកែទម្រង់ក្នុងដំណាក់កាលទាំង២ វិធានការត្រួតពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីកែទម្រង់កាន់តែមានភាពប្រាកដប្រជាជាងមុន ដូចមានចែងលម្អិតនេះនៅក្នុងសារាចរ រាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យ តាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

### ២.៤. ពាក្យគន្លឹះ

ដើម្បីឈានទៅរកការសិក្សាស្រាវជ្រាវលម្អិតបន្ថែមពាក់ព័ន្ធនឹងប្រធានបទនេះ ពាក្យគន្លឹះសំខាន់ៗត្រូវបានពន្យល់ ដើម្បីដើរតួជាផ្នែកមួយនៃលក្ខណៈវិនិច្ឆ័យក្នុងការវាយតម្លៃទៅលើប្រធានបទនេះ។

| ពាក្យគន្លឹះ | អត្ថន័យ | ប្រភពដកស្រង់ |
|---|---|---|
| ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | សំណុំនៃច្បាប់បទដ្ឋានប្រព័ន្ធ និងនីតិវិធីសម្រាប់គ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ដំណើរការនៃការគ្រប់គ្រងធនធានហិរញ្ញវត្ថុសាធារណៈរួម មានការរៀបចំគោលនយោបាយ ការកៀរគរធនធានហិរញ្ញវត្ថុ ការវិភាជថវិកា ការអនុវត្តចំណាយ ការធ្វើកិច្ចបញ្ជិកា និងការធ្វើសវនកម្ម។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home/ |
| គណនេយ្យភាពហិរញ្ញវត្ថុ | ការទទួលខុសត្រូវចំពោះមុខច្បាប់លើការគ្រប់គ្រងថវិកា និងការគ្រប់គ្រងហិរញ្ញវត្ថុស្របតាមបទបញ្ញត្តិទាំងឡាយដែលជាធរមាន។ ដើម្បីធានាបាននូវគណនេយ្យភាពហិរញ្ញវត្ថុចាំបាច់ត្រូវមានការរៀបចំប្រព័ន្ធតាមដាន ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ប្រកបដោយសុក្រឹត្យភាព អាចទុកចិត្តបានទាន់ពេលវេលា។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| ថវិកាកម្មវិធី | គឺជាប្រភេទមួយនៃថវិកាដែលការរៀបចំផ្អែកលើកម្មវិធីច្បាស់លាស់ ដើម្បីឈានទៅសម្រេចគោលបំណងគោលនយោបាយក្រសួង-ស្ថាប័ន ស្របតាមគោលនយោបាយដែលមានចែងក្នុងវិស័យនីមួយៗ។ ជារួមថវិកាកម្មវិធីខុសពីថវិកាតាមបន្ទាប់មាតិកាដោយសារការរៀបចំថវិកាត្រូវបានផ្សារភ្ជាប់ទៅនឹងលទ្ធផល ឬសមិទ្ធកម្ម | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |

| | | |
|---|---|---|
| | របស់ក្រសួង-ស្ថាប័ននីយមួយៗ ដោយធ្វើការផ្លាស់ប្តូរការរៀបចំថវិកាដែលធ្លាប់តែផ្តោតលើធាតុចូល។ | |
| **ភាពជឿទុកចិត្តបាន** | សំដៅដល់ព័ត៌មាន(ឬទិន្នន័យ) អំពីថវិកាដែលត្រូវមានភាពពេញលេញគ្រប់ជ្រុងជ្រោយត្រឹមត្រូវ និងមានសង្គតិភាព។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **គណនេយ្យភាពសមិទ្ធកម្ម** | គឺជាការទទួលខុសត្រូវចំពោះលទ្ធផលនៃការអនុវត្តដែលបានព្រមព្រៀង ឬសន្យានៅពេលដែលថវិកាស្នើសុំនៅចំពោះមុខគណៈរដ្ឋមន្ត្រីនិងស្ថាប័ននីតិប្បញ្ញត្តិ។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ចក្ខុវិស័យ** | គឺជាទស្សនទានទូលំទូលាយមួយដែលបង្ហាញពីបំណងប្រាថ្នារយៈពេលវែង។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **យុទ្ធសាស្ត្រ** | គឺជាវិធីសាស្ត្រមានលក្ខណៈជាប្រព័ន្ធ និងជាជំហានៗដែលរៀបចំឡើងសម្រាប់សម្រេចបាននូវទិសដៅគោលនយោបាយ ដែលបានដាក់ចេញ។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ថវិកាជាតិ ឬថវិការដ្ឋ** | ថវិកាជាតិ ឬថវិការដ្ឋ រួមមានថវិកាថ្នាក់ជាតិ ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ថវិកាឧបសម្ព័ន្ធ និងគណនីពិសេសរតនាគារជាតិ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ថវិកាសមិទ្ធកម្ម** | ថវិកាសមិទ្ធកម្ម សំដៅដល់ប្រព័ន្ធថវិកាដែលមានគោលបំណងក្នុងការបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធិភាពនៃចំណាយសាធារណៈ តាមរយៈការផ្សារភ្ជាប់ការវិភាជថវិកាសម្រាប់អង្គភាពសាធារណៈទៅនឹងលទ្ធផលដែលសម្រេចបាន ដោយប្រើប្រាស់ព័ត៌មានសមិទ្ធកម្មដែលមានលក្ខណៈជាប្រព័ន្ធ។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ផែនការសកម្មភាពរួម** | ក្របខ័ណ្ឌសកម្មភាពរួមដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ននីមួយៗ ត្រូវអនុវត្តនៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្របខ័ណ្ឌត្រូវបានបែងចែកជាបីកម្រិត គឺ ១.ផ្នែក ២.គោលបំណង និង ៣.ចង្កោមសកម្មភាព។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ការតាមដានកម្រិតបច្ចេកទេស** | ក្របខណ្ឌសកម្មភាពរួមដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ននីមួយៗ ត្រូវអនុវត្តនៅក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្របខណ្ឌត្រូវបានបែងចែកជាបីកម្រិត គឺ (១).ផ្នែក, (២).គោលបំណង និង (៣).ចង្កោមសកម្មភាព។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |

| | | |
|---|---|---|
| **ផែនការប្រតិបត្តិការថវិកា** | គឺជាផែនការលម្អិតសម្រាប់ការអនុវត្តថវិកាប្រចាំឆ្នាំ ដូចគ្នាទៅនឹងកម្មវិធីចំណូល-ចំណាយដែរ។ ប៉ុន្តែផ្តោតជាចាំបាច់ក្នុងការជំរុញការអនុវត្តសកម្មភាពនៅក្រោមកម្មវិធីនីមួយៗ។ នីតិវិធីប្រតិបត្តិ ផ្សារភ្ជាប់គ្នារវាងការអនុវត្តហិរញ្ញវត្ថុ និងកម្មវិធី។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ផែនការយុទ្ធសាស្ត្រថវិកា** | ការរៀបចំផែនការថវិកាពីក្រោមឡើងទៅលើ ឬពីក្រោមក្រសួង-ស្ថាប័ន ដើម្បីសម្រេចបានគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល។ ផែនការយុទ្ធសាស្ត្រថវិកានេះ ធ្វើឡើងរយៈពេលបីឆ្នាំ ដោយផ្តល់នូវការធ្វើវិភាជបឋមមុនពេលរៀបចំកញ្ចប់លម្អិត និងរួមបញ្ចូលគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, កម្មវិធី ឬយុទ្ធសាស្ត្រអាទិភាព, សូចនាករ និងគោលដៅសូចនាករ, និងការបែងចែកធនធានចរន្ត និងធនធានមូលធនទាំងថវិការដ្ឋ និងថវិកាដៃគូអភិវឌ្ឍន៍។ | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |
| **ផែនការសមិទ្ធកម្មប្រចាំឆ្នាំ** | គឺជាឯកសារគ្រោងសមិទ្ធកម្មដែលភ្ជាប់ជាមួយសេចក្តីព្រាងច្បាប់ថវិកា។ តាមកម្មវិធីនីមួយៗ ឯកសារនេះបង្ហាញពីសកម្មភាព, ចំណាយពាក់ព័ន្ធនានា, គោលបំណង, សូចនាករ, លទ្ធផលដែលសម្រេចបាននិងគោលដៅសម្រាប់ឆ្នាំបន្ទាប់, ការវាយតម្លៃចំណាយសារពើពន្ធ, អំណះអំណាងនៃកំណើនឥណទានធៀបជាមួយនឹងការអនុវត្តចំណាយឆ្នាំចាស់ទៅនឹងឥណទានឆ្នាំបច្ចុប្បន្ន។ ឯកសារនេះក៏បង្ហាញផងដែរនូវការកំណត់កាលវិភាគនៃឥណទានមានកម្រិតកំណត់ជាមួយនឹងឥណទានថវិកាជានាចំណាយ ព្រមទាំងក្រុមចំណាយ ឬប្រភេទនៃកិច្ចសន្យា, ការប៉ាន់ស្មានលម្អិតនៃប្រាក់បៀវត្សរបស់មន្ត្រីរាជការ និងអំណះអំណាងនៃការផ្លាស់ប្តូរឥណទាន និងចំនួនបុគ្គលិកសម្រាប់អនុវត្តកម្មវិធី | សន្ទានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា(ឆ្នាំ២០២១) https://lexicon-gdb.legalcouncilmef.com/home |

## ២.៥. ទិដ្ឋភាពទូទៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

### ២.៥.១. ភាពជឿទុកចិត្តនៃថវិកា

ថវិកាកាន់តែមានភាពជឿទុកចិត្ត និងបានក្លាយជាចលករ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តល់អាទិភាពបន្ទាន់លើការងារពង្រឹងការប្រមូល ការគ្រប់គ្រង

ចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ យើងបានដាក់ចេញនិងជំរុញការអនុវត្តវិធានការជាច្រើន ដែលនាំឱ្យយើងសម្រេចដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ (រាជរដ្ឋាភិបាលកម្ពុជា, ២០០៤)។

### ២.៥.២. ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

ប្លង់គណនេយ្យថ្មីសម្រាប់រដ្ឋាភិបាល និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបានកែសម្រួលឱ្យស្របតាមស្តង់ដាអន្តរជាតិ និងដាក់ឱ្យអនុវត្ត។ លុបបំបាត់មុខងារបេឡានៅរតនាគារទាំងស្រុង ដោយបង្វែរមកប្រើប្រាស់សេវារបស់ធនាគារជាតិនៃកម្ពុជា។ តម្លាភាពថវិកា ត្រូវបានបង្កើនជាលំដាប់ តាមរយៈការផ្សព្វផ្សាយនូវឯកសារសំខាន់ៗ រួមមាន៖ **១.**សង្ខេបសំណើថវិកាដែលបានអនុម័តដោយគណៈរដ្ឋមន្ត្រី **២.**ថវិកាសង្ខេបប្រកបដោយភាពសាមញ្ញ និងងាយស្រួលយល់ត្រូវបានរៀបចំបន្ទាប់ពីច្បាប់ថវិកាត្រូវបានអនុម័ត **៣.**របាយការណ៍ស្តីពីលទ្ធផលនៃការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំឆមាស **៤.**ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ **៥.**របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំ **៦.**របាយការណ៍សវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ **៧.**ព្រឹត្តបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និង **៨.**ផែនការលទ្ធកម្មសាធារណៈ សេចក្តីជូនដំណឹងការដេញថ្លៃ ការប្រគល់កិច្ចសន្យាលទ្ធកម្ម និងរបាយការណ៍ត្រួតពិនិត្យកិច្ចលទ្ធកម្មសាធារណៈតាមក្រោយ ដែលស្ថិតនៅក្រោមសិទ្ធិសម្រេចលើស្ថាប័នអនុវត្តលទ្ធកម្ម ឬអង្គភាពថវិកាប្រចាំឆ្នាំ២០១៦ លើការិយបរិច្ឆេទឆ្នាំ២០១៥។ តាមរយៈការផ្តល់ព័ត៌មានស្តីពីថវិកានៅគ្រប់វដ្តនៃថវិកាជាសាធារណៈ គឺដើម្បីពង្រឹងប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពថវិកាផងដែរ។ រហូតមកដល់ពេលនេះ ប្រព័ន្ធ FMIS ត្រូវបានបញ្ចប់អនុវត្តសាកល្បងនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយ ហើយកំពុងតែពង្រីកការអនុវត្តសាក ល្បងទៅដល់ក្រសួង ស្ថាប័ន ជាបន្តបន្ទាប់។ ក្នុងពេលអនាគត ប្រព័ន្ធនេះ នឹងក្លាយជាយន្តការស្នូល ក្នុងការពង្រឹងប្រសិទ្ធភាពថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុ នៅគ្រប់កម្រិតទាំងកម្រិតនៃការត្រួតពិនិត្យហិរញ្ញវត្ថុ កម្រិតនៃការគ្រប់គ្រង សាច់ប្រាក់ និងកម្រិតនៃការអនុវត្តកម្មវិធី (រាជរដ្ឋាភិបាលកម្ពុជា, ២០០៩)។

### ២.៥.៣. ប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ថវិកាកម្មវិធីសាកល្បងពេញលេញ ត្រូវបានអនុវត្ត និងពង្រីកទៅគ្រប់ក្រសួង-ស្ថាប័ន។ គ្រប់ក្រសួង-ស្ថាប័ន បានរៀបចំរចនាសម្ព័ន្ធគោលនយោបាយ និងផែនការយុទ្ធសាស្ត្រថវិកា។ ក្របខ័ណ្ឌគតិយុត្តនៃការរៀបចំ និងអនុវត្តថវិកាកម្មវិធី ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត។ យន្តការអង្គភាពថវិកាបានជំរុញឱ្យមានតម្លាភាព គណនេយ្យភាព ការផ្ទេរសិទ្ធិអំណាច និងការទទួលខុសត្រូវ និងការចូលរួមខ្ពស់ពីអង្គភាពជំនាញក្នុងការនៃវដ្តថវិកា។

តាមរយៈការអនុវត្តថវិកាកម្មវិធីពេញលេញនៅគ្រប់ក្រសួង-ស្ថាប័ន ចាប់ពីឆ្នាំ ២០១៨ តទៅ នឹងជួយដល់ក្រសួង-ស្ថាប័នធ្វើការរៀបចំថវិកាកាន់តែផ្សារ ភ្ជាប់ទៅនឹងគោលនយោបាយ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ ការរៀបចំថវិកា និងការចរចាថវិកា ត្រូវបានពង្រឹង និងកែលម្អមួយកម្រិតខ្ពស់ថែមទៀត តាមរយៈការឆ្លុះបញ្ចាំងបានកាន់តែល្អប្រសើរឡើងនូវអាទិភាពសំខាន់ៗរបស់រាជរដ្ឋាភិបាល ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត(រាជរដ្ឋាភិបាលកម្ពុជា, ២០១៦)។

### ២.៥.៤. កសាងគណនេយ្យភាពសមិទ្ធកម្ម

ការកសាងគណនេយ្យភាពសមិទ្ធកម្ម មានគោលបំណងរៀបចំ និងដាក់ឱ្យដំណើរការនូវសមាសធាតុនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ ដើម្បីកែលម្អការគ្រប់គ្រងការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។

ក្នុងក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ បានកំណត់ក្របខ័ណ្ឌវិធីសាស្ត្រយន្តការនិងនីតិវិធីនៃការតាមដាននិងវាយតម្លៃការអនុវត្តថវិកា។ ក្នុងនោះអង្គភាពសាធារណៈទាំងអស់ ត្រូវរៀបចំគម្រោងថវិកានឹងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ដែលឯកសារទាំងនេះជាកម្មវត្ថុនៃការពិនិត្យអនុលោមភាពនឹងការផ្តល់អនុសាសន៍កែលម្អដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

## ២.៥. ស្នូលសំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

ស្នូលសំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បង្ហាញពីគោលបំណង និងសកម្មភាពការងារកែទម្រង់កម្រិតយុទ្ធសាស្ត្រដែលជាឯកសារមូលដ្ឋានសម្រាប់អង្គភាពនីមួយៗ ក្នុងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ ក្នុងការរៀបចំផែនការសកម្មភាពលម្អិតរបស់ខ្លួន។ ស្នូលសំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានចំនួន ៥ផ្នែកដូចខាងក្រោម៖

- ផ្នែកទី១៖ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា
- ផ្នែកទី២៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ
- ផ្នែកទី៣៖ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- ផ្នែកទី៤៖ ការកសាងគណនេយ្យភាពសមិទ្ធកម្ម
- ផ្នែកទី៥៖ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត។

### ២.៥.១. ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា

ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា មានគោលបំណងពង្រីកលំហហិរញ្ញវត្ថុសាធារណៈ (Fiscal Space) ដើម្បីទ្រទ្រង់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍និងសម្រេចនូវកំណើនសេដ្ឋកិច្ចខ្ពស់។ លទ្ធផលនៃផ្នែកទី១ នេះ គឺសម្រេចឱ្យបាននូវចីរភាពហិរញ្ញវត្ថុសាធារណៈ (Fiscal Sustainability) ក្នុងបរិបទដែលស្ថិរភាពនៃម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈកម្ពុជា បាននិងកំពុងរងឥទ្ធិពលពីភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកល។ ចីរភាពហិរញ្ញវត្ថុសាធារណៈ នឹងត្រូវឆ្លុះបញ្ចាំងតាមរយៈភាពទន់មាំនៃកំណើនថវិកា ដែលត្រូវបានអនុវត្តប្រចាំត្រីមាសនិងឆ្នាំ ប្រកបដោយភាពរលូននិងអាចប៉ាន់ប្រមាណបានស្ថិតនៅក្នុងរង្វង់ +/-៥% នៃច្បាប់ថវិកា។ បន្ថែមពីនេះ ផ្នែកនេះនឹងជំរុញការកែទម្រង់ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៤ រួមមាន៖ ១.ការបង្កើតការប្រមូលចំណូល ២.ការពង្រឹងប្រសិទ្ធភាពនការអនុវត្តថវិកា ៣.ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ទី២ និង ៤.ការពង្រឹងការគ្រប់គ្រងបន្ទុកសារពើពន្ធ (Tax Expenditure)។ លើសពីនេះ ការប្រមូលចំណូល នៅតែជាអាទិភាពស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ផ្អែកតាមយុទ្ធសាស្ត្រកៀរគរចំណូល ការសម្រេចបានគោលដៅនៃការប្រមូលចំណូលប្រចាំឆ្នាំឱ្យបានយ៉ាងតិច ០,៣ ពិន្ទុភាគរយធៀបនឹង

ផលិតផលក្នុងស្រុកសរុប គឺជាមូលដ្ឋានដ៏ចាំបាច់ ក្នុងការទ្រទ្រង់ថវិកាចំណាយប្រតិបត្តិការនិងបង្កើនការវិធិយោគសាធារណៈ។ ក្នុងន័យនេះ ផែនការសកម្មភាពរួម ជំរុញការកែលម្អគោលនយោបាយ និងរដ្ឋបាលសារពើពន្ធ ដើម្បីកៀរគរចំណូលឱ្យអស់សក្តានុពលនិងផ្តល់ការលើកទឹកចិត្តផ្នែកសារពើពន្ធឱ្យចំគោលដៅសម្រាប់ការលើកកម្ពស់ភាពប្រកួតប្រជែងនិងការបង្កើនផលិតភាពសេដ្ឋកិច្ចជាតិ។ ក្រៅពីនេះ ចំពោះការគ្រប់គ្រងថវិកាចំណាយវិញ ផែនការសកម្មភាពរួមបានពង្រឹងការរៀបចំ និងអនុវត្តផែនការថវិកាដោយគ្រប់គ្រងសាច់ប្រាក់នឹងបង្ការមិនឱ្យមានចំណាយកកស្ទះ ពន្លឿនដំណើរការនៃការអនុវត្តនិងការទូទាត់ចំណាយដោយបង្កើនការប្រើប្រាស់ប្រព័ន្ធធនាគារនិងប្រព័ន្ធ E-transfer ហើយបន្តកែលម្អដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈ ដោយធ្វើវិមជ្ឈការសិទ្ធិសម្រេចលទ្ធកម្មនិងពង្រឹងការរៀបចំនិងអនុវត្តផែនការលទ្ធកម្មសាធារណៈ (រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

### ២.៥.២. ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ មានគោលបំណងធ្វើស្វ័យប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និងពង្រឹងប្រព័ន្ធគណនេយ្យសាធារណៈកម្ពុជាឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ ដើម្បីអាចផលិតរបាយការណ៍ហិរញ្ញវត្ថុ និងរៀបចំច្បាប់ទូទាត់ថវិកាទាន់ពេលវេលា និងអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ។ លទ្ធផលនៃផ្នែកទី២ នេះ គឺសម្រេចឱ្យបាននូវការពង្រីកការដ្ឋានប្រើប្រាស់មុខងារប្រព័ន្ធ FMIS ហើយធានាថាទិន្នន័យស្តីពីធនធានហិរញ្ញវត្ថុសាធារណៈ រួមមានៈ ថវិការដ្ឋ ទ្រព្យសម្បត្តិរដ្ឋ បំណុលសាធារណៈ និងស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ មានវិសាលភាពគ្រប់ជ្រុងជ្រោយនឹងអាចប្រើប្រាស់សម្រាប់ការត្រួតពិនិត្យ និងពិនិស្វ័យ។ ទន្ទឹមនេះ ផ្នែកនេះនឹងជំរុញការកែទម្រង់លើលទ្ធផលចុងក្រោយចំនួន ៥ រួមមាន៖**១.**ការធ្វើស្វ័យប្រវត្តិកម្ម ប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **២.** ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងច្បាប់ទូទាត់ថវិកា **៣.**ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ **៤.**ការគ្រប់គ្រងបំណុលសាធារណៈ និង **៥.** ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ។ ជាមួយគ្នានេះ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣ បានកំណត់ឱ្យមានការប្រើប្រាស់ប្រព័ន្ធ FMIS តែមួយគត់សម្រាប់គ្រប់គ្រង រៀបចំ អនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តចំណូល-ចំណាយថវិការដ្ឋ និងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ព្រមទាំងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។ អង្គភាពសាធារណៈទាំងអស់ រួមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំនិងផ្តល់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយ-ការណ៍និងឯកសារដែលពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុនិងគណនេយ្យនៃថវិការដ្ឋ ដើម្បីផ្ទៀងផ្ទាត់ និងរៀបចំជាច្បាប់ហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ផែនការសកម្មភាពរួម ផ្តល់អាទិភាពសំខាន់លើការពង្រីកការដ្ឋានប្រើប្រាស់ប្រព័ន្ធ FMIS ដោយអភិវឌ្ឍមុខងារបន្ថែម និងធ្វើសន្ទានកម្មជាមួយប្រព័ន្ធពាក់ព័ន្ធ ហើយពង្រឹងគុណភាពទិន្នន័យនិង អនុលោមភាពនៃការរៀបចំរបាយការណ៍របស់អង្គភាពសាធារណៈទាំងអស់ ឱ្យស្របតាមការកំណត់នៃច្បាប់ ពោលគឺ ថវិកាចំណូល-ចំណាយ (ចរន្ត និងវិនិយោគ) និងចលនាឥណទានត្រូវអនុវត្តទាំងស្រុងតាមនីតិវិធីនៃប្រព័ន្ធ FMIS បាយការណ៍អនុវត្តថវិកាប្រចាំត្រីមាសនិងប្រចាំឆ្នាំអាចផលិតពីប្រព័ន្ធ FMIS ទិន្នន័យទ្រព្យសម្បត្តិរដ្ឋនឹងបំណុលសាធារណៈ ត្រូវបានឆ្លុះបញ្ចាំងក្នុងប្រព័ន្ធ FMIS និងរបាយការណ៍និងច្បាប់ហិរញ្ញវត្ថុរបស់ជាតិ ត្រូវ

បានរៀបចំប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ទាន់ពេលវេលា និងអនុលោមតាមស្តង់ដាគណនេយ្យសាធារណៈ(រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

### ២.៥.៣.ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ការពង្រឹងប្រសិទ្ធភាពការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ មានគោលបំណងពង្រឹងការរៀបចំ គម្រោងថវិកាឱ្យមានព័ត៌មានកាន់តែគ្រប់ជ្រុងជ្រោយ ដើម្បីអាចតម្រឹមធនធានហិរញ្ញវត្ថុជាមួយនឹងអាទិភាព គោលនយោបាយនិងកម្មវិធីវិនិយោគសាធារណៈរបស់រាជរដ្ឋាភិបាល។ លទ្ធផលផ្នែកទី៣នេះ គឺត្រូវសម្រេចឱ្យបាននូវការអនុម័តក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម (MTFF) និងក្របខ័ណ្ឌថវិការយៈពេលមធ្យម (MTBF) ហើយជំរុញការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) និងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ឱ្យមានរចនាសម្ព័ន្ធកម្មវិធីនិងព័ត៌មានសមិទ្ធកម្មច្បាស់លាស់ ព្រមទាំងឆ្លុះបញ្ចាំងនូវគម្រោងចំណូលនឹងចំណាយគ្រប់មុខសញ្ញាទាំងថវិកាចរន្ត និងវិនិយោគតាមកម្មវិធីផងដែរ។ លើសពីនេះ ផ្នែកនេះនឹងជំរុញការកែទម្រង់ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៤ រួមមាន៖ **១.**ការកែលម្អការរៀបចំផែនការថវិការយៈពេលមធ្យម **២.**ការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាផារណៈ **៣.**ការកែលម្អប្រសិទ្ធភាពនៃការគ្រោងថវិកា (ថវិកាកម្មវិធី) និង **៤.**ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយគ្នាការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិ និងតាមវិស័យរបស់រាជរដ្ឋាភិបាល ត្រូវរក្សាភាពទន់ភ្លន់ដើម្បីឆ្លើយតបទៅនឹងបរិការណ៍និងស្ថានភាពនៃការអនុវត្តជាក់ស្តែង។ ក្របខ័ណ្ឌ MTFF និង MTBF គឺជាការកំណត់អាទិភាពចំពោះមុខរបស់រាជរដ្ឋាភិបាលសម្រាប់អង្គភាពសាធារណៈទាំងអស់ ក្នុងការរៀបចំនិង អនុវត្តកម្មវិធីអភិវឌ្ឍន៍តាមវិស័យនិងតាមសមត្ថកិច្ចរៀងៗខ្លួន។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ អនុវត្តកម្មវិធីអភិវឌ្ឍន៍តាមវិស័យនិងតាមសមត្ថកិច្ចរៀងៗខ្លួន។ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឆ្នាំ២០២៣ បានកំណត់នូវវិធាននិងដំណើរការនៃការរៀបចំ BSP និងគម្រោងថវិកាប្រចាំឆ្នាំ ហើយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវរៀបចំបែបបទនិងនីតិវិធីណែនាំលម្អិត។ ជាមួយគ្នានេះ ផែនការសកម្មភាពរួមក៏បានជំរុញការកែលម្អគុណភាពនៃការរៀបចំគម្រោងថវិការបស់អង្គភាពសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយផ្តោតការយកចិត្តទុកដាក់លើការអនុម័តក្របខ័ណ្ឌ MTFF និង MTBF បានកំណត់ពិដានចំណាយគោល ការធ្វើសមាហរណកម្មថវិកាចរន្តនិងថវិកាវិនិយោគ ការពង្រឹងយន្តការពិនិត្យលើគម្រោងវិនិយោគសាធារណៈ ការរៀបចំចំណាយតាមកម្មវិធីឱ្យមានរចនាសម្ព័ន្ធ និងការទទួលខុសត្រូវច្បាស់លាស់ និងពង្រឹងមុខងារត្រួតពិនិត្យការអនុវត្តថវិកា (រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

### ២.៥.៤.ការកសាងគណនេយ្យភាពសមិទ្ធកម្ម

ការកសាងគណនេយ្យភាពសមិទ្ធកម្ម មានគោលបំណងរៀបចំ និងដាក់ឱ្យដំណើរការនូវសមាសធាតុនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មជាបណ្តើរៗ ដើម្បីកែលម្អការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។ លទ្ធផលផ្នែកទី៤នេះ គឺត្រូវសម្រេចឱ្យបាននូវការបញ្ចប់ការរៀបចំបទដ្ឋានគតិយុត្តសំខាន់ៗអំពីវិធាន និងនីតិវិធីនៃដំណើរការប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម និងការធ្វើវិមជ្ឈការសិទ្ធិអំណាចក្នុងការអនុវត្តថវិកាជូនដល់អង្គភាពថវិកាដែលមានលក្ខណៈសម្បត្តិសមស្រប ព្រមទាំងការពង្រឹង

គណនេយ្យភាពតាមរយៈ ការអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម ការលើកកម្ពស់តម្លាភាពថវិកា និង ការកែលម្អប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងផ្ទៃក្រៅ។ ជាងនេះទៅទៀត ផ្នែកទី៤ នេះ ជំរុញការកែទម្រង់ ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៣ រួមមាន៖ ១.ការដាក់ឱ្យអនុវត្តវិធាននិងនីតិវិធីនៃប្រព័ន្ធ ថវិកាព័ត៌មានសមិទ្ធកម្ម ២.ការកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យ អធិការកិច្ច និងសវនកម្ម និង ៣.ការលើកកម្ពស់តម្លាភាពថវិកា។ បន្ថែមពីនេះ ក្នុងក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្មក្នុងច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣ បានកំណត់ក្របខ័ណ្ឌវិធីសាស្ត្រ យន្តការ និងនីតិវិធីនៃការ តាមដាននិងវាយតម្លៃការអនុវត្តថវិកា។ ក្នុងនោះអង្គភាពសាធារណៈទាំងអស់ ត្រូវរៀបចំគម្រោងថវិកា និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ដែលឯកសារទាំងនេះ ជាកម្មវត្ថុនៃការពិនិត្យអនុលោមភាពនិង ការផ្តល់អង្គាសន៍កែលម្អដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជាមួយគ្នានេះ ផែនការសកម្មភាពរួម ជំរុញការរៀបចំបញ្ចប់នូវលិខិតបទដ្ឋានគតិយុត្តនានា ដែលពាក់ព័ន្ធនឹងវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការរៀបចំរបាយការណ៍ និងការត្រួតពិនិត្យតាមដាននិងវាយតម្លៃ ថវិកាសមិទ្ធកម្ម ព្រមទាំង រៀបចំយន្តការសម្រាប់អនុវត្តកិច្ចប្រចាំថ្ងៃ កិច្ចព្រមព្រៀងសមិទ្ធកម្ម (Performance Agreement) ជាមួយគ្នានេះ ផែនការសកម្មភាពរួម។ ពង្រឹងការអនុវត្តងារអធិការកិច្ចហិរញ្ញវត្ថុនិងសវនកម្មផ្ទៃក្នុង ព្រមទាំងលើកកម្ពស់ការរៀបចំ និងផ្សព្វផ្សាយឯកសារថវិកា ដើម្បីធានានូវតម្លាភាពនិងគណនេយ្យ ភាពចំពោះអង្គនីតិប្បញ្ញត្តិ និងសាធារណជន(រាជរដ្ឋាភិបាលកម្ពុជា, ២០២៣)។

### ២.៥.៥.ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងទៀត

ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេង ទៀត មានគោលបំណងពង្រឹងការអនុវត្តយន្តការលើកទឹកចិត្ត និងគ្រប់គ្រងសមិទ្ធកម្មការងារកែទម្រង់ របស់អង្គភាពអនុវត្ត ដើម្បីបណ្តុះភាពជាម្ចាស់និងអភិវឌ្ឍសមត្ថភាពក្នុងការដឹកនាំនិងអនុវត្តការងារកែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពង្រឹងយន្តការសម្របសម្រួលរវាងការដ្ឋានកែទម្រង់ដទៃ ទៀត។ លទ្ធផលផ្នែកទី៥នេះ គឺត្រូវពង្រឹងភាពជាអ្នកដឹកនាំ ភាពជាម្ចាស់ និងសមត្ថភាពរបស់អង្គភាព សាធារណៈ ក្នុងការគ្រប់គ្រង ការកំណត់ និងអនុវត្តសកម្មភាពកែទម្រង់ស្របតាមចក្ខុវិស័យនឹងយុទ្ធ សាស្ត្ររបស់រាជរដ្ឋាភិបាល ដើម្បីរក្សាចលនការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងភាព ប្រទាក់ក្រឡាជាមួយនឹងគ្រប់ការដ្ឋានកែទម្រង់ពាក់ព័ន្ធ។ ជាមួយគ្នានេះ ផ្នែកនេះជំរុញការកែទម្រង់ ដើម្បីសម្រេចលទ្ធផលចុងក្រោយចំនួន៤ រួមមាន៖ ១.ការលើកកម្ពស់ភាពជាអ្នកដឹកនាំនិងសមត្ថភាព របស់អង្គភាពសាធារណៈ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ២.ការធានា ចលនការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៣.ការសម្រប សម្រួលកម្មវិធីកែទម្រង់ ៣បូក១ របស់រាជរដ្ឋាភិបាល និង ៤.ការបង្កើនសមិទ្ធកម្មការងាររបស់មន្ត្រីសាធារណៈ។ ជាមួយគ្នា នេះ ផែនការកម្មភាពរួម ផ្តោតលើការពង្រឹងអនុលោមភាពនៃការអវត្តសារាចរ ០៩ របស់រាជរដ្ឋាភិបាល ដោយបន្តកែលម្អការរៀបចំនិងអនុវត្តផែនការសកម្មភាពកែទម្រង់ និងជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រង គណនេយ្យភាពនិងសមិទ្ធកម្ម (Performance Management and Accountability System; PMAS) សម្រាប់សម្រួលដល់ការរៀបចំផែនការសកម្មភាពនិងរបាយការណ៍សមិទ្ធកម្ម។ ម្យ៉ាងវិញទៀត ផែនការ សកម្មភាពរួម ក៏នឹងផ្តោតទៅលើការបង្កើនកិច្ចសម្របសម្រួលជាមួយកម្មវិធីកែទម្រង់ពាក់ព័ន្ធ ដើម្បី

កំណត់ចក្ខុវិស័យនិងផែនការសកម្មភាពកែទម្រង់រួម ពិសេសលើការជំរុញវិមជ្ឈការហិរញ្ញវត្ថុ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងលក្ខខណ្ឌយោងការងារមន្ត្រីសាធារណៈទូទាំងប្រទេសសម្រាប់អនុវត្តការពិនិត្យសមិទ្ធកម្មការងារ ការផ្ដល់ការលើកទឹកចិត្ត និងការអភិវឌ្ឍគុណវឌ្ឍិរបស់មន្ត្រី (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២៣)។

## ២.៦. ការសិក្សាសម្មតិកម្ម

នៅក្នុងការសិក្សាស្រាវជ្រាវមួយត្រូវបានបែងចែកឱ្យដាច់រវាងអថេរពីរគឺ អថេរឯករាជ្យ និងអថេរពឹងផ្អែក។ ដោយអថេរទាំង ២ នេះបានដើរតួរយ៉ាងសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវ និងអាចនាំឱ្យការសិក្សាស្រាវជ្រាវ មានភាពច្បាស់លាស់ជាងមុន និងងាយស្រួលក្នុងការប្រមូលឯកសារ និងទិន្នន័យជាពិសេសការរៀបចំកម្រងសំណួរនៃប្រធានបទនីមួយៗ។ នៅក្នុងប្រធានបទនេះ ត្រូវបានតាងអថេរឯករាជ្យ និងអថេរពឹងផ្អែកនឹងបានទាញចេញនូវសម្មតិកម្មសំខាន់ៗរួមមាន៖

នៅក្នុងការតាងរបស់អថេរឯករាជ្យ និងអថេរពឹងផ្អែកបានធ្វើឱ្យយើងអាចទាញបាននូវសម្មិតកម្មសំខាន់ៗ ចំនួន ០៥ រួមមាន៖

**សម្មតិកម្ម១៖** ការបន្តរពង្រឹងភាពជឿទុកចិត្តនៃថវិកា។

**សម្មតិកម្ម២៖** ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ។

**សម្មតិកម្ម៣៖** ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។

**សម្មតិកម្ម៤៖** ការកសាងគណនេយ្យសមិទ្ធកម្ម។

**សម្មតិកម្ម៥៖** ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ។

| Dimensions | Sub Dimensions |
|---|---|
| ការបន្តរពង្រឹងភាពជឿទុកចិត្តនៃថវិកា | - ការបង្កើនការប្រមូលចំណូល<br>- ការកែលម្អការអនុវត្តថវិកា<br>- ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ<br>- ការគ្រប់គ្រងបន្ទុកសារពើពន្ធ |
| ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ | - ការធ្វើស្វ័យប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងច្បាប់ទូទាត់<br>- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ<br>- ការគ្រប់គ្រងបំណុលសាធារណៈ<br>- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណរដ្ឋបាល និងសហគ្រាសសាធារណៈ |

| | |
|---|---|
| ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | - ការកែលម្អការរៀបចំផែនការថវិការយៈពេលមធ្យម<br>- ការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈ<br>- ការកែលម្អប្រសិទ្ធភាពនៃការគ្រោងថវិកា<br>- ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ |
| ការកសាងគណនេយ្យសមិទ្ធកម្ម | - ការរៀបចំវិធាន និងនីតិវិធីនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម<br>- ការកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យ<br>- ការលើកកម្ពស់តម្លាភាពថវិកា |
| ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ | - ការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមត្ថភាពរបស់អង្គភាពក្នុងការអនុវត្តកម្មវិធីកែទម្រង់<br>- ការជានាចលនាការនៃការកែទម្រង់ការគ្រប់គ្រង<br>ហិរញ្ញវត្ថុសាធារណៈ<br>- ការសម្របសម្រួលកម្មវិធីកែទម្រង់ ៣បូក១<br>- ការកែលម្អសមិទ្ធកម្មការងាររបស់មន្ត្រីរាជរដ្ឋាភិបាល |

**តារាងទី 1** ៖Dimensions Sub Dimensions Study

### ២.៧. ការរំលឹកវិធីសាស្ត្រស្រាវជ្រាវ

យោងតាមការរំលឹកទ្រឹស្តី ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យសមិទ្ធកម្ម និងការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ គឺជាអថេរមិនឯករាជ្យ (IV) និងប្រសិទ្ធភាពនៃកម្មវិធីកែទម្រង់ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅព្រះរាជាណាចក្រកម្ពុជាគឺជាអថេរឯករាជ្យ (DV)។



# ជំពូកទី៣
# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ៣.១.ទិដ្ឋភាពទូទៅ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី១បានចាប់ផ្តើមឡើងនៅចុងឆ្នាំ ២០០៤ ដោយផ្តោតលើ "**ការកសាងភាពជឿទុកចិត្តបាននៃថវិកា**" ហើយដែលត្រូវបានអនុវត្តរហូតដលឆ្នាំ ២០០៨ ដោយសម្រេចបាននូវសមិទ្ធផលគន្លឹះជាមូលដ្ឋានសម្រាប់ការបោះជំហានឡើងមកកាន់ដំណាក់កាល បន្ទាប់ នោះគឺ ការដោះស្រាយបានដោយជោគជ័យ នូវបញ្ហាបំណុលសាច់ប្រាក់ដ៏រ៉ាំរ៉ៃ ការអនុវត្តពេញលេញ នូវប្រព័ន្ធគណនីទោលរតនាគារជាតិ ការធ្វើទំនើបកម្មច្បាប់ស្តីពីប្រព័ន្ធដើរញ្ញវត្ថុសាធារណៈ ការកែទម្រង់កិច្ចលទ្ធកម្មសាធារណៈ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ជាដើម។ ទាំងអស់នេះ គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់ និងជាមួយបុរេលក្ខខណ្ឌ មិនអាចខ្វះបានសម្រាប់ការចាប់ផ្តើមដំណាក់កាលទី២ដោយផ្តោតលើ "**ការកសាងគណនេយ្យភាពហិរញ្ញវត្ថុ**" ដែលត្រូវបានអនុវត្តពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥។ ដំណាក់កាលទី២ នេះ ត្រូវបានអនុវត្តតាមរយៈក្របខ័ណ្ឌផែនការសកម្មភាពរយៈពេល ៥ឆ្នាំ និងបន្ទាប់ពីបានឆ្លងការវាយតម្លៃ ត្រូវបានបន្ថែមសកម្មភាពសម្រាប់អនុវត្ត រយៈពេលប្រមាណ ២ ឆ្នាំបន្តទៀត ដោយសម្រេចបាននូវសមិទ្ធផ ជាសារវ័ន្តមួយចំនួនជាអាទិ៍៖ ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគា ការពង្រីកអង្គភាពសវនកម្មផ្ទៃក្នុង ការអភិវឌ្ឍប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) និងការចាប់ផ្តើមលោកល្បងអនុវត្តប្រព័ន្ធថវិកាកម្មវិធីនៅតាមក្រសួងមួយចំនួន។ បន្ទាប់ពីបានវាយតម្លៃយ៉ាងម៉ត់ពត់លើវឌ្ឍនភាពរយៈពេល ៧ឆ្នាំ នៃដំណាក់កាលទី២ រួចមក រាជរដ្ឋាភិបាលបានសម្រេចចាប់ផ្តើមអនុវត្តដំណាក់កាលទី៣ ដែលជាដំណាក់កាលយុទ្ធសាស្ត្រដ៏សំខាន់មួយទៀត ដោយផ្តោតលើ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**"។ ដំណាក់កាលទី៣ នេះ ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០១៦ មក។ យ៉ាងណាមិញ ដោយសារកត្តាសត្យានុម័តជាច្រើន ជាពិសេស បញ្ហាវិបត្តិជំងឺកូវិត៥-១៩, គោលដៅគន្លឹះមួយចំនួននៃដំណាក់កាលទី៣ មិនអាចសម្រេចបានតាមកាលកំណត់ឡើយ ដែលជាហេតុតម្រូវឱ្យមានការពន្យារពេល តាមរយៈការដាក់ចេញនូវក្របខ័ណ្ឌផែនការសកម្មភាពដំណាក់កាលទី៣ នេះ ចំនួន ២ ឆ្នាំបន្ថែមទៀត គឺពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ មុននឹងយើងអាចចាប់ផ្តើមអនុវត្តដំណាក់កាលទី៤ ដែលផ្តោត លើ "គណនេយ្យភាពសមិទ្ធកម្ម" នៅក្នុងឆ្នាំ២០២៣។

ក្របខ័ណ្ឌច្បាប់ និងបទប្បញ្ញត្តិសំខាន់ដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានដូចខាងក្រោម៖រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣,ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ច្បាប់ស្តីពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ, ព្រះរាជក្រឹត្យ លេខ នសរកត១២១៣១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អនុក្រឹត្យលេខ ២៣. អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អនុក្រឹត្យលេខ ២៤ អនុក្រ.បក ចុះថ្ងៃទី១៧ ខែ

មករា ឆ្នាំ២០១៤ អនុក្រឹត្យស្តីពីការរៀបចំនឹងប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, សេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី ៣ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលេខ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ប្រកាសស្តីពីការបង្កើតគណៈកម្មការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលេខ ១២២ សហវ.ប្រក ប្រកាសស្តីពីការបង្កើតការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលខ ១២២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈឆ្នាំ២០០៨ ប្រកាសស្តីពីការបង្កើតការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលេខ ១២០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ប្រកាសស្តីពីការកែសម្រួល ២១៨ សហវ.ប្រក ប្រកាសស្តីពីការបង្កើតគណៈកម្មការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលេខ ២១៩ សហវ.ប្រក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៩ ប្រកាសស្តីពីការបង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលេខ ២៤២ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា, ប្រកាសលេខ ០៤៨ សហវ សគហ សេចក្តីសម្រេចស្តីពីការដាក់ឱ្យអនុវត្តវិធីសាស្ត្រវាយតម្លៃ និងការកំណត់ទម្ងន់ចង្កោម គោលបំណង និងផ្នែកនៃក្របខ័ណ្ឌផែនការសកម្មភាពរួម, ប្រកាសលេខ ៨៥៦ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា, ទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០, ប្រកាសលេខ ១៨៩ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ក្រោមជាតិនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ, ប្រកាសលេខ ២១១ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តមាតិកាគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ, ប្រកាសលេខ ៧២០ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា, សារាចរណ៍ណែនាំលេខ ០០៦ សហវ. សារាចរស្តីពីការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, សារាចរណ៍ណែនាំលេខ ០៩ សវ សារាចរ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ប្រកាសលេខ ១៣០៩ សហវ.ប្រក ប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការ, អនុក្រឹត្យលេខ ៤៦៨ អនក្រ បក អនុក្រឹត្យស្តីពីការបង្កើតបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ ក្របខ័ណ្ឌគ ឋានន្តរស័ក្តិទី២ និងក្របខ័ណ្ឌគ ឋានន្តរស័ក្តិទី២, ប្រកាសលេខ ១៩១១ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី, ប្រកាសលេខ ០៦៨ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ, ប្រកាសលេខ ១៥៨៩ សហវ.ប្រក ប្រកាសស្តីពីវិធាន និងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់ថ្នាក់ជាតិ, ប្រកាសលេខ ២២៣ សហវ.ប្រក ប្រកាសស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដ្ឋាន, ប្រកាសលេខ ០៤៨ សហវ សគហ សេចក្តីសម្រេច ស្តីពីការដាក់ឱ្យអនុវត្តវិធី

សាស្ត្រវាយតម្លៃ និងការកំណត់ទម្ងន់ចង្កោម គោលបំណង និងផ្នែកនៃក្របខណ្ឌផែនការសកម្មភាពរួម , យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៣, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ ២០១៨, កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី១ ឆ្នាំ២០០៤, កម្មវិធីកែទម្រង់ការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី២ ឆ្នាំ២០០៩, ចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី៣ ឆ្នាំ២០១៦, ចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី៤ ២០២៣-២០២៧ ឆ្នាំ២០២៣, ចក្ខុវិស័យនិងយុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មកែទម្រង់ ៣ បូក ១, រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២២, ចក្ខុវិស័យនិងយុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្មកែទម្រង់ ៣ បូក ១, រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០២២, យុទ្ធសាស្ត្រនៃការកែ ទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោម ជាតិឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ ២០២៥, យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥, យុទ្ធសាស្ត្រ កៀរគរចំណូល ២០១៩-២០២៣, ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥។

## ៣.២. រចនាសម្ព័ន្ធ និងយន្តការ

### ៣.២.១.រចនាសម្ព័ន្ធ



### ៣.២.២. យន្តការស្ថាប័ន

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងដំណាក់កាលទី៤ ត្រូវបានគាំទ្រ និងអនុវត្តដោយយន្តការស្ថាប័នរួមមាន៖ **១**.គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) **២**.គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (**គ.គ.ហ.**) **៣**.ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ប្រចាំក្រសួង-ស្ថាប័ន **៤**.ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ប្រចាំរដ្ឋបាលរាជធានី-ខេត្ត **៥**.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) **៦**.យន្តការអន្តរកែទម្រង់ និង **៧**.យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍។ យន្តការ ស្ថាប័នទាំងនេះ មានបង្ហាញដូចខាងក្រោម៖

#### ៣.២.២.១. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤។ តាមរយៈសេចក្តីសម្រេចលេខ២០ សសរ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **គ.ហ.ស.** មានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាប្រធាន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ជាអនុប្រធានព្រមទាំងថ្នាក់ដឹកនាំមួយរូបពីគ្រប់ក្រសួង-ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសមាជិក។ **គ.ហ.ស.** បំពេញភារកិច្ចដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍។ យោងតាមសារាចររាជរដ្ឋាភិបាលលេខ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ **គ.ហ.ស.** មានកិច្ចប្រជុំប្រចាំត្រីមាសនិង ប្រចាំឆ្នាំ ដែលជាវេទិកាកម្រិតនយោបាយក្នុងការត្រួតពិនិត្យតាមដានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង-ស្ថាប័ននីមួយៗ។

#### ៣.២.២.២.គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

តាមរយៈប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាស្ថាប័នស្នូលក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា បានបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.គ.ហ.**)។ តាមរយៈសេចក្តីសម្រេចលេខ ០៣៦ សហវ.ស.ស.អគហ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣ ស្តីពីការតែងតាំងសមាសភាពគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.គ.ហ.**) ស្ថិតក្រោមការដឹកនាំដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានសមាសភាពពីថ្នាក់ដឹកនាំក្រសួងនឹងប្រធាននៃគ្រប់អង្គភាពក្រោមឱវាទក្រសួងជាអនុប្រធាន និងជាសមាជិក។ **គ.គ.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងវាយតម្លៃការ

អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ **គ.គ.ហ.** ជាស្ថាប័នកម្រិតបច្ចេកទេស ដែលដើរតួជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនត្រឹមតែក្នុងការពិនិត្យសម្រេចលើចក្ខុវិស័យ គោលបំណង កម្មវិធី ផែនការសកម្មភាព ការរៀបចំនិង តាមដានការអនុវត្តផែនការសកម្មភាពរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាអ្នកសម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្តទៀតផង។ ទន្ទឹមនេះ **គ.គ.ហ.** ក៏ជាចំណុចប្រមូលផ្តុំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងការកៀរគរជំនួយនឹងការសម្របសម្រួល ការអនុវត្តកម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមួយដៃគូអភិវឌ្ឍន៍នានា។ លើសពីនេះ **គ.ក.ហ.** ក៏ជាគណៈកម្មការដឹកនាំផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុផងដែរ ដែលក្នុងនោះ **គ.ក.ហ.** ត្រួតពិនិត្យលើការងារកែទម្រង់របស់ក្រុមការងារកែទម្រង់២ គឺ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំអគ្គនាយកដ្ឋាននិងអង្គភាពក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុថ្នាក់កណ្តាល និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.៣.២.៣. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមាន **ក.ហ.ស.** មួយប្រចាំក្រសួង ស្ថាប័នរបស់ខ្លួន ដែលត្រូវបានដឹកនាំដោយផ្ទាល់ពីតំណាងនៃក្រសួង ស្ថាប័ន ០១រូប ដែលជាសមាជិក **គ.ហ.ស.** ហើយដែលត្រូវជារដ្ឋលេខាធិការឬអនុរដ្ឋលេខាធិការឬថ្នាក់ដឹកនាំមួយរូបដែលទទួលបន្ទុកជួយរដ្ឋមន្ត្រីឬប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន។ **គ.ហ.ស.** ជាក្រុម ការងារបច្ចេកទេស ដែលមានភារកិច្ចដឹកនាំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំ ក្រសួង-ស្ថាប័នរបស់ខ្លួន ព្រមទាំងជាអ្នកសម្របសម្រួលរៀបចំនិងកែតម្រូវផែនការសកម្មភាពលម្អិតប្រចាំ ក្រសួង-ស្ថាប័នរបស់ខ្លួន ឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម។

### ៣.៣.២.៤. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំរដ្ឋបាលរាជធានី-ខេត្ត

ដោយសារតែការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងដំណាក់កាលនេះ មានគណនេយ្យភាពសមិទ្ធកម្មជាស្នូល ហើយដែលសមិទ្ធកម្មនោះមិនសំដៅដល់ត្រឹមតែជាសមិទ្ធកម្មរបស់មន្ត្រីនិងស្ថាប័ននៅ ថ្នាក់ជាតិនោះ **គ.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី ខេត្ត នឹងត្រូវបានបង្កើតឡើងក្នុងគោលបំណងពង្រឹងការ ទទួលខុសត្រូវលើសមិទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **គ.ហ.ស.** ជាក្រុមការងារបច្ចេកទេស ដែលមានភារកិច្ចដឹកនាំនិងអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈប្រចាំរដ្ឋបាលរាជធានី-ខេត្តរបស់ខ្លួន ព្រមទាំងជាអ្នកសម្របសម្រួលរៀបចំនិងកែតម្រូវផែនការ សកម្មភាពលម្អិតប្រចាំរដ្ឋបាលរាជធានី-ខេត្តរបស់ខ្លួនឱ្យមានសង្គតិភាពជាមួយផែនការសកម្មភាពរួម។

ថ្នាក់ដឹកនាំ **គ.ហ.ស.** ប្រចាំរដ្ឋបាលរាជធានី-ខេត្ត នឹងត្រូវជាសមាជិក **គ.ហ.ស.** ហើយដែលថ្នាក់ ដឹកនាំនោះអាចជាអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត ឬ ជាប្រធានក្រុមប្រឹក្សារាជធានី ខេត្ត។

### ២.៣.២.៥.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អនុលោមតាមអនុក្រឹត្យលេខ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការឱ្យ **គ.ហ.ស.**។ ក្នុងការបំពេញមុខងាររបស់ខ្លួន **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** រួមទាំងការរៀបចំដាក់ឱ្យអនុវត្តនិងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **អ.គ.ហ.** ក៏មានតួនាទីស្នូលក្នុងការជំរុញការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង ស្ថាប័ន និងប្រចាំរដ្ឋបាលរាជធានី-ខេត្ត ព្រមទាំងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ **អ.គ.ហ.** ក៏ជាសេនាធិការឱ្យ **គ.ក.ហ.** ក្នុងសហការ និងសម្របសម្រួលជាមួយ **ក.ហ.ស.** ប្រចាំអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីជំនួយដល់ការរៀបចំផែនការសកម្មភាពលម្អិត និងតាមដានការអនុវត្តការកែទម្រង់របស់ **ក.ហ.ស.** ប្រចាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

### ៣.៣.២.៦.យន្តការអន្តរកែទម្រង់

យន្តការអន្តរកែទម្រង់សំដៅដល់កម្មវិធីកែទម្រង់ ៣បូក១។ កម្មវិធីកែទម្រង់ ៣បូក១ ជាកម្មវិធីកែទម្រង់ ដែលសំដៅមិនត្រឹមតែកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប៉ុណ្ណោះទេ តែជាកម្មវិធី ដែលមានលក្ខណៈប្រទាក់ក្រឡា ជាមួយកម្មវិធីកែទម្រង់ដទៃទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងនោះ មានកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ យន្តការអន្តរកែទម្រង់ ឬហៅម្យ៉ាងទៀតថា យន្តការសម្របសម្រួលការកែទម្រង់ ៣ បូក ១ នៃរាជរដ្ឋាភិបាល ឬហៅកាត់ថា **យ.ស.ក.** ត្រូវបានប្រកាសដាក់ឱ្យអនុវត្តតាមរយៈអនុក្រឹត្យលេខ២៤១ អនក្រ.បក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីយន្តការសម្រប សម្រួលការកែទម្រង់ ៣បូក១ នៃរាជរដ្ឋាភិបាលដែលមានវិសាលភាពអនុវត្ត ចំពោះការកែទម្រង់ទាំងអស់ របស់រាជរដ្ឋាភិបាលដែលមានទំនាក់ទំនងជាមួយនឹង កម្មវិធីកែទម្រង់ទាំង៤ នេះ ។

កម្មវិធីកែទម្រង់ ៣បូក១ ខាងលើ គឺស្ថិតនៅក្រោមសមត្ថកិច្ចដាច់ដោយឡែកៗ នៅតាមក្រសួងនីមួយៗ។ ក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដឹកនាំសម្របសម្រួលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួងមហាផ្ទៃដឹកនាំសម្របសម្រួលកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈដឹកនាំសម្របសម្រួលកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងយុត្តិធម៌ដឹកនាំសម្របសម្រួលកម្មវិធីកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ទំនាក់ទំនងនៃកម្មវិធីកែទម្រង់ទាំងនេះ អាចមើលឃើញក្រោមរូបភាពប្រទាក់ក្រឡារវាងមុខងារ ហិរញ្ញវត្ថុ ធនធានមនុស្ស និងទិដ្ឋភាពច្បាប់និងប្រព័ន្ធយុត្តិធម៌។

**យ.ស.ក.** ជាយន្តការដឹកនាំនិងសម្របសម្រួលផ្លាស់វេនប្រចាំត្រីមាសរវាង **អ.គ.ហ.** លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (**គ.ជ.អ.ប.**) លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ (**គ.គ.រ.**) និងលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (**គ.ច.ប្រ.**)។ **យ.ស.ក.** មានជាផែនការ សកម្មភាពប្រចាំត្រីមាសនិងប្រចាំឆ្នាំ និងមានរបបប្រជុំប្រចាំត្រីមាសដែលដឹកនាំដោយប្រធានផ្លាស់វេន។

**៣.៣.២.៧. យន្តការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍**

ដើម្បីឱ្យការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដើរស្របជាមួយឧត្តមានុវត្តន៍អន្តរជាតិ ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ប.ហ.**) ឬជាភាសាអង់គ្លេស Public Financial Management Technical Working Group (PFM-TWG) ត្រូវបានបង្កើតឡើង ក្នុងគោលបំណងធ្វើជាយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈរបស់រាជរដ្ឋាភិបាល។ **ក.ប.ហ.** មានសមាសភាពមកពី **គ.ហ.ស.** ដែលតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា និងគណៈកម្មាធិការដៃគូអភិវឌ្ឍន៍ (Development Partner Committee; DPC) ដែលតំណាងឱ្យ ដៃគូអភិវឌ្ឍន៍។ DPC ផ្ដល់អនុសាសន៍ក្នុងការរៀបចំផែនការសកម្មភាពរួម ដំណាក់កាលទី៤ និងផ្ដល់អនុសាសន៍លើរបាយការណ៍តាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ក.ប.ហ.** មានរបបប្រជុំប្រចាំត្រីមាសនិងប្រចាំឆ្នាំ ដែលត្រូវដឹកនាំដោយប្រធាន **គ.ហ.ស.** និងមានការចូលរួមពីតំណាងដៃគូអភិវឌ្ឍន៍។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទាំងក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត។

## ៣.៣. សមត្ថភាពស្ថាប័ន

នៅក្នុងក្របខ័ណ្ឌកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សមត្ថភាពស្ថាប័នជាសមាសធាតុសំខាន់ក្នុងការសម្រេចនូវគោលដៅចុងក្រោយនៃកម្មវិធីកែទម្រង់គឺ **"គណនេយ្យភាពសមិទ្ធកម្ម"**។ សមត្ថភាពស្ថាប័ន សំដៅលើភាពជាអ្នកដឹកនាំ ភាពជាម្ចាស់ ឆន្ទៈ និងសមត្ថភាពជំនាញបច្ចេកទេសក្នុងការចូលរួម និងគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ ប្រកបដោយភាពជោគជ័យ និងចីរភាព។

ក្នុងដំណាក់កាលទី៣ កន្លងមក ក្រសួង ស្ថាប័នប្រមាណ ៥% ដែលមានសមាសភាពប្រធានក្រុមការងារកែទម្រង់ជាប្រធានស្ថាប័ន បានជំរុញឱ្យការចូលរួមការងារកែទម្រង់មានភាពល្អប្រសើរ ទាំងសមិទ្ធផលការងារ និងភាពទាន់ពេលវេលានៃការធ្វើផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាព។ ចំពោះក្រសួង ស្ថាប័នប្រមាណជាង ៦០% ដែលមានប្រធានក្រុមការងារជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ វឌ្ឍនភាពការងារស្ថិតក្នុងកម្រិតល្អទៅល្អប្រសើរលើភាពទាន់ពេលវេលានៃការធ្វើរបាយការណ៍ និងការចូលរួមផ្សេងៗ។ ក្រសួង ស្ថាប័នប្រមាណ ៣០% ទៀត ដែលមានសមាសភាពប្រធានក្រុមការងារកែទម្រង់ត្រឹមជា អគ្គលេខាធិការ/ អគ្គនាយក/អគ្គនាយករងឬតំណែងប្រហាក់ប្រហែល មានវឌ្ឍនភាពការងារនិងការចូលរួមផ្សេងៗនៅក្នុងកម្រិតមធ្យមទៅល្អ។

ទិដ្ឋភាពនេះបានបង្ហាញថា កម្រិតថ្នាក់ដឹកនាំចូលរួមកាន់តែខ្ពស់ ឆ្លុះបញ្ចាំងពីឆន្ទៈកែទម្រង់ និងការយកចិត្តទុកដាក់របស់ក្រសួង ស្ថាប័ន កាន់តែខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ យន្តការផ្តល់ប្រាក់ឧបត្ថម្ភ លើកទឹកចិត្តជូនក្រុមការងារកែទម្រង់ក៏បានចូលរួមចំណែកក្នុងការធ្វើឱ្យមានភាពកាន់តែល្អប្រសើរនៃសមិទ្ធកម្ម ការងារផងដែរ។ នៅក្នុងរយៈពេល៣ឆ្នាំចុងក្រោយពោលពីឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ការផ្តល់ប្រាក់ឧបត្ថម្ភ លើកទឹកចិត្តបានកើនឡើងជារួមប្រមាណ ២០% ធៀបជាមួយនឹងឆ្នាំកន្លងមក ដែលក្នុងនោះ ចំនួនក្រុមការងារ កែទម្រង់ ដែលត្រូវទទួលប្រាក់ឧបត្ថម្ភបានកើនឡើងបន្ថែមដល់ ១៣២ នាក់នៅឆ្នាំ២០២២។ ខណៈដែលការលើកទឹកចិត្តត្រូវបានបង្កើន សមិទ្ធផលការងារនិងការចូលរួមនានាពីក្រុមការងារកែទម្រង់ក្នុងរយៈពេលដូចគ្នា ក៏មានភាពរលូននិងល្អប្រសើរគួរឱ្យកត់សម្គាល់ផងដែរ។ ក្នុងន័យនេះ ឆន្ទៈជំរុញការងារពីថ្នាក់ដឹកនាំ កត្តាសំខាន់មិនអាចខ្វះបាន តែការលើកទឹកចិត្តដល់ក្រុមការងារ ទាំងផ្នែកហិរញ្ញវត្ថុ (ឧទាហរណ៍៖ ការផ្តល់ ប្រាក់ឧបត្ថម្ភបន្ថែម) និងមិនមែនហិរញ្ញវត្ថុ (ឧទាហរណ៍៖ ការផ្តល់មុខតំណែងការងារខ្ពស់ជាងមុន) ក្នុងការអនុវត្តការងារកែទម្រង់ក៏ជាកត្តាសំខាន់ផងដែរ។

ស្របជាមួយនឹងឆន្ទៈ ភាពជាម្ចាស់ និងភាពជាដឹកនាំ សមត្ថភាពនៃការយល់ដឹងពីជំនាញបច្ចេកទេសនិងជំនាញទន់របស់មន្ត្រីសាធារណៈនៃក្រសួង-ស្ថាប័ន ជាការគាំទ្រសំខាន់ដល់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្ពោះទៅរកភាពជោគជ័យ និងនិរន្តរភាពការងារ។ ដូចនេះ "**ផែនការយុទ្ធសាស្ត្រកសាងនិងអភិវឌ្ឍន៍សមត្ថភាព**" ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងនិងកសាងសមត្ថភាព ជូនថ្នាក់ដឹកនាំនិងមន្ត្រីកែទម្រង់ តាមរយៈការកំណត់នូវមុខជំនាញបណ្តុះបណ្តាលសំខាន់ៗសម្រាប់ធានា ប្រសិទ្ធភាពអនុវត្តការងារ ដូចជា ជំនាញថវិកាសមិទ្ធកម្ម លទ្ធកម្មសាធារណៈ ព្យាករណ៍ចំណូល និងគ្រប់គ្រងការវិនិយោគសាធារណៈ ព្រមទាំងជំនាញទន់ផ្សេងៗ ពាក់ព័ន្ធនឹងការបណ្តុះឆន្ទៈ ភាពជាម្ចាស់ ភាពជាអ្នកដឹកនាំ។ ផែនការយុទ្ធសាស្ត្រនេះ ក៏បានកំណត់ទិសដៅរៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលឌីជីថល ដើម្បីទំនើបកម្មការរៀបចំវគ្គបណ្តុះបណ្តាល និងពង្រឹងការអភិវឌ្ឍធនធានមនុស្សស្របតាមសម័យកាលបដិវត្ត ឧស្សាហកម្មឌីជីថល។ ក្រៅពីផែនការយុទ្ធសាស្ត្រនេះ មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមក្រសួង-ស្ថាប័ន ត្រូវបានគិតគូរកំណត់ក្របខ័ណ្ឌមុខតំណែងការងារហិរញ្ញវត្ថុនិងគុណវឌ្ឍិច្បាស់លាស់ តាមរយៈការដាក់ចេញអនុក្រឹត្យកំណត់លក្ខខណ្ឌតែងតាំងផ្សេងៗ មុននឹងចូលទៅកាន់មុខតំណែងការងារហិរញ្ញវត្ថុណាមួយនៅក្នុងក្រសួង-ស្ថាប័ន។

ជាទិសដៅទៅមុខ សមត្ថភាពស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ត្រូវបន្តពង្រឹង និងគិតគូរ បន្ថែមពីលើវឌ្ឍនភាពដែលមាននាពេលបច្ចុប្បន្ន។

### ៣.៣.១. ការបន្តជំរុញភាពជាម្ចាស់ នឹងឆន្ទៈ នៃការចូលរួមកម្មវិធីកែទម្រង់

ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ចាំបាច់ត្រូវត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្មការងារនិង ការចូលរួមកន្លងមករបស់ក្រុមការងារកែទម្រង់របស់ខ្លួន និងពិចារណាពិនិត្យលទ្ធភាពជំរុញក្រុមការងារ ដូចខាងក្រោម៖១.រៀបចំចាត់តាំងរចនាសម្ព័ន្ធក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលមានការចូលរួមពីប្រធានស្ថាប័ន,២.ផ្តល់យន្តការលើកទឹកចិត្ត ជាប្រាក់ឧបត្ថម្ភជាការបណ្តុះបណ្តាល ឬផ្តល់កាលានុវត្តភាព ណាមួយជូនក្រុមការងារកែទម្រង់របស់ខ្លួន បន្ថែមពី

លើប្រាក់ឧបត្ថម្ភដែលផ្តល់ដោយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ៣.គួរផ្តល់អាទិភាពខ្ពស់ ដល់មន្ត្រីបង្គោល ក្នុងការចាត់តាំងចូលរួមកិច្ចប្រជុំពាក់ព័ន្ធ វគ្គបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស និងសកម្មភាពការងារផ្សេងៗដែលទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ការជ្រើសរើសសមាសភាពក្រុមការងារកែទម្រង់ ជាពិសេសមន្ត្រីបង្គោល គួរផ្អែកលើជំនាញវិជ្ជាជីវៈ និងបទពិសោធន៍។ ជាមួយគ្នានេះ ក្រុមការងារកែទម្រង់របស់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត គួរមានសមាសភាពពីអង្គភាពជំនាញពាក់ព័ន្ធ ដូចជា អង្គភាពរដ្ឋបាលហិរញ្ញវត្ថុ អង្គភាពលទ្ធកម្ម សវនកម្ម ទ្រព្យសម្បត្តិរដ្ឋ។

### ៣.៣.២.ការបន្តពង្រឹងការរៀបចំក្របខ័ណ្ឌកសាងសមត្ថភាពធនធានមនុស្ស៖

ខណៈដែលសមត្ថភាពថ្នាក់ដឹកនាំ និងមន្ត្រី ក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី-ខេត្ត ត្រូវបានពង្រឹងតាមរយៈការបណ្តុះបណ្តាលជាបន្តបន្ទាប់ វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជាសេនាធិការកសាងសមត្ថភាពនៅក្នុងក្របខ័ណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវរៀបចំក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃឱ្យបានច្បាស់លាស់ អំពីសមត្ថភាពក្នុងការអនុវត្តការងាររបស់មន្ត្រីសាធារណៈ និងវាស់ស្ទង់ពីឆន្ទៈនៃការចូលរួមការងារកែទម្រង់ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ។ ក្នុងន័យនេះ វិទ្យាស្ថាននឹងអាចវាយតម្លៃសមត្ថភាពធនធានមនុស្សជាក់លាក់ ដើម្បីកំណត់ជាទិសដៅតម្រូវការបណ្តុះបណ្តាល និងការរៀបចំតតិយុត្តដែលចាំបាច់នានានៅថ្ងៃមុខ។

ក្រៅពីការគិតគូរពង្រឹងសមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីកែទម្រង់នៃក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី- ខេត្ត សមត្ថភាពថ្នាក់ដឹកនាំនិងមន្ត្រីនៅក្នុងស្ថាប័ននីតិប្បញ្ញត្តិ ក៏ចាំបាច់ត្រូវពង្រឹងផងដែរដោយប្រើប្រាស់ក្របខ័ណ្ឌបណ្តុះបណ្តាលមួយសមស្រប។

អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលជានិម្មាបនករនៅក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវចូលរួមចែករំលែកចំណេះដឹងនិងបទ-ពិសោធន៍ អនុវត្តការងារហិរញ្ញវត្ថុជូនក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានីខេត្ត។ ការងារនេះ ត្រូវរៀបចំជាយន្តការប្រឹក្សាយោបល់ និងវេទិកាចែករំលែកបទពិសោធន៍នានាជូនក្រសួង ស្ថាប័ន។

ការរៀបចំក្របខ័ណ្ឌការងារបច្ចុប្បន្ននិងទិសដៅការងារបន្ត ត្រូវបានរំពឹងថាសមត្ថភាពស្ថាប័ននៅក្នុងក្របខ័ណ្ឌការងារកែទម្រង់នឹងមានការអភិវឌ្ឍថែមមួយកម្រិតទៀត ទាំងសមត្ថភាពបច្ចេកទេស វិជ្ជាជីវៈ ឆន្ទៈ ភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់។

# ជំពូកទី៤
# វិធីសាស្ត្រស្រាវជ្រាវ

## ៤.១.សេចក្តីផ្តើម

គោលបំណងនៃជំពូកនេះគឺដើម្បីពន្យល់ពីវិធីសាស្ត្រដែលត្រូវបានប្រើក្នុងការសិក្សាបច្ចុប្បន្ន។ សម្រាប់គោលបំណងនៃជំពូកនេះត្រូវបានចែកជា ៦ ផ្នែក។ ផ្នែកទី១ ការកំណត់ទំហំសំណាក និងបច្ចេកទេសជ្រើសរើសសំណាក ផ្នែកទី២ ប្រភេទ និងប្រភពទិន្នន័យ ផ្នែកទី៣ ឧបករណ៍ក្នុងការវិភាគទិន្នន័យ ផ្នែកទី៤ នីតិវិធីនៃការប្រមូលទិន្នន័យ នៅផ្នែកទី៥ បរិយាយ និងការគណនាពីភាពទុកចិត្តនៃកម្រងសំណួរ និងផ្នែក៦ ចុងក្រោយជាសេចក្តីសន្និដ្ឋាន។

## ៤.២.ការជ្រើសរើសសំណាក និងប៉ាន់គំរូ

ការប្រមូលសំណាកត្រូវបានជ្រើសរើសប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងខណ្ឌទួលគោកតែប៉ុណ្ណោះ។ ការគណនាទំហំគំរូ ត្រូវបានអនុវត្តតាមរូបមន្ត Taro Yamane (១៩៦៧) ដែលត្រូវបានប្រើប្រាស់សម្រាប់គណនា និងត្រូវបានសន្មតសម្រាប់រូបមន្តនេះ។ ការគណនាទំហំសំណាកតម្រូវឱ្យធ្វើតាមរូបមន្តលោក Taro Yamane (១៩៦៧) ដូចខាងក្រោម៖

តាមរូបមន្ត៖ $n = \frac{N}{១+Ne^{២}}$

- n = ចំនួនមន្ត្រីសរុបដែលត្រូវបានស្ទង់មតិ
- N = ចំនួនមន្ត្រីសរុបនៅអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- e = ភាពលម្អៀង (ប្រូបាប៊ីលីតេ)

កម្រិតភាពពេញចិត្ត ៩៥% និងភាពលម្អៀង ៥% ត្រូវបានសន្មតសម្រាប់រូបមន្តនេះផងដែរ។ ផ្អែកតាមអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានមន្ត្រីចំនួន ៥៧រូប ឆ្នាំ២០២៤។ ទំហំសំណាក៖

គេបាន $n = \frac{57}{1+57x0.05^2} = 49.89 \approx 50$ រូប

## ៤.៣.ប្រភពទិន្នន័យ

នៅក្នុងការស្រាវជ្រាវនេះ ត្រូវបានប្រើប្រាស់ទាំងវិធីសាស្ត្រតាមបែបគុណវិស័យ ដែលទិន្នន័យទាំងអស់ត្រូវបានប្រមូលតាមរយៈការសង្កេត ការស្ទង់មតិពីមន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈ Google Forms (Google Forms, 2024)។

ការប្រមូលទិន្នន័យ គឺមានសារៈសំខាន់ណាស់ម្រាប់ធ្វើការសិក្សាស្រាវជ្រាវ និងប្រមូលឯកសារមកចងក្រង ដើម្បីរៀបរៀងឡើងក្នុងការបំពេញឱ្យគ្រប់លក្ខខណ្ឌ និងយកមកសរសេរនិក្ខេបបទទ្រឹស្តីដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ឱ្យប្រកបដោយភាពជោគជ័យ និងប្រសិទ្ធភាពខ្ពស់។ ដើម្បីប្រមូលបានទិន្នន័យល្អៗ និងគ្រប់គ្រាន់ទៅតាមគោលបំណងចង់បាននោះ ក្នុងដំណាក់កាលនេះត្រូវធ្វើការប្រមូលទិន្នន័យតាមប្រភពពីរ គឺទិន្នន័យចំបង(Primary Data) និងទិន្នន័យបន្ទាប់បន្សំ (Secondary Data)។

ទិន្នន័យចំបង (Primary Data) គឺជាប្រភេទទិន្នន័យទាំងឡាយណាដែលបានការស្ទង់មតិពីមន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈ Google Forms ដោយប្រើបញ្ជីសំណួរ (Questionnaires)។ ចំណុចសំខាន់នៃទិន្នន័យចំបង គឺដើម្បីទទួលបាននូវព័ត៌មានល្អ និងមានគុណភាព និងអាស្រ័យទៅលើបញ្ជីសំណួរ និងការស្ទង់មតិស្របតាមស្ថានភាពជាក់ស្តែងពីមន្ត្រីចំនួន ៥០រូប របស់អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ទិន្នន័យបន្ទាប់បន្សំ (Secondary Data) គឺជាប្រភេទទិន្នន័យដែលបានមកពិការស្រាវជ្រាវច្បាប់បទប្បញ្ញត្តិ ឯកសារ និងរបាយការណ៍ផ្សេងៗដែលពាក់ព័ន្ធទៅនឹងប្រធានបទ។ ទិន្នន័យទាំងនេះបានដក់ស្រង់មកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អត្ថបទផ្សព្វផ្សាយ និងឯកសារផ្សេងៗតាមរយៈអ៊ិនធើណែត សៀវភៅ និងបណ្ណាល័យ។

## ៤.៤.ឧបករណ៍ក្នុងការវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបានពីដំណើរការនៃការប្រមូលទិន្នន័យតាមរយៈការចុះស្រង់មតិពីប្រជាពលរដ្ឋត្រូវបានយកមកវិភាគតាមបែបវិទ្យាសាស្ត្រដែលមានលក្ខណៈជាក់លាក់ អាចប្រើប្រាស់បាន និងមានប្រភពជាក់លាក់។ នៅក្នុងការវិភាគទិន្នន័យ ត្រូវបានជ្រើសរើសការវិភាគបែបគុណវិស័យដែលជាការវិភាគដោយយកទិន្នន័យតាមរយៈអត្ថបទច្បាប់ និងឯកសារនានា ជាមួយនឹងការសម្ភាសន៍ដោយប្រើប្រាស់នូវឧបករណ៍ដើម្បីវិភាគទៅលើកម្រងសំណួរ តាមរយៈការវិភាគ Mean, Frequency និង Regression តាមកម្មវិធី SPSS។ ទន្ទឹមនឹងនេះ ការវិភាគតាមបែបគុណវិស័យ គឺត្រូវបានវិភាគដោយការប្រមូលយកទិន្នន័យដែលទទួលបានពីលទ្ធផលនៃការសម្ភាសន៍ និងការអង្កេតដើម្បីបម្លែងពីទិន្នន័យទៅជាអត្ថន័យបែបសង្ខេប (IBM, 2017)។

## ៤.៥.វិធីសាស្ត្រក្នុងការជ្រើសរើសគំរូ

ក្នុងការជ្រើសរើសគំរូធ្វើឡើងតាមរយៈការសាកសួរដោយរៀបចំជាកម្រងសំណួរ ដើម្បីធ្វើការស្ទង់មតិពីមន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមរយៈ Google Forms បង្កើតជាសំណួរបើក និងសំណួរបិទ។ ការស្ទង់មតិ ដើម្បីប្រមូលយកទិន្នន័យមានរយៈពេលចំនួន ៥ថ្ងៃ និងបានស្នើសុំមន្ត្រីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការចំណាយពេលវេលាបំពេញកម្រងសំណួរក្នុងកម្មវិធី Google Forms។ ការរៀបចំកម្រងសំណួរត្រូវបានរៀបចំតាមម៉ូឌែលអថេរមិនឯករាជ្យ IV ផង និងអថេរមិនឯករាជ្យ DV ផងដែរ។

## ៤.៦.នីតិវិធីក្នុងការប្រមូលទិន្នន័យ

កម្រងសំណួរ នឹងរួមបញ្ចូលសំណួរស្តីពិទិដ្ឋាភាពជាច្រើនទាក់ទងនឹងប្រធានបទនៃការស្រាវជ្រាវដូចជា អត្តសញ្ញាណរបស់អ្នកឆ្លើយសំណួរដែលទាក់ទងទៅនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឥទ្ធិពលនៃកម្មវិធីកែទម្រង់នៅព្រះរាជាណាចក្រកម្ពុជា។ ក្នុងដំណើរការ

រៀបចំកម្រងសំណួរ សំណួរនីមួយៗសម្រាប់អថេរខាងលើបានផ្ទៀងផ្ទាត់ និងពិនិត្យទិន្នន័យឡើងវិញយ៉ាងច្បាស់ និងទទួលបានទិន្នន័យស្វ័យមតិពីកម្មវិធី Google Forms ជាទម្រង់ Excel ។ លើសពីនេះមុនពេលកម្រងសំណួរត្រូវបានប្រើសម្រាប់ប្រមូលទិន្នន័យបឋមពីអ្នកឆ្លើយតបនឹងសំណួរទៅតាមទំហំដែលបានកំណត់រួចមកសេចក្តីព្រាងកម្រងសំណួរនេះ ត្រូវបានធ្វើតេស្តសាកល្បងមុននឹងដាក់ឱ្យប្រើប្រាស់ និងបានធ្វើការសាលល្បងវិភាគតាមរយៈកម្មវិធី SPSS ក្នុងកុំព្យូទ័រ ដើម្បីបញ្ជាក់ឱ្យបានច្បាស់ថារង្វាស់ដែលបានប្រើតាមអថេរនីមួយៗ មានភាពបន្សុំគ្នាទៅនឹងឧបករណ៍ស្ថិតិដែលបានគ្រោងទុក ឬបើអាចខុសឆ្គងពាក្យពេចន៍ ខ្លឹមសារនៃសំណួរណាមួយងាយនឹងមានការកែតម្រូវចាំបាច់ជាមុន ទើបការសម្រេចចិត្តទិន្នន័យតាមទំហំសំណាកពិតប្រាកដត្រូវអនុវត្ត។

## ៤.៧.ភាពជឿជាក់នៃទិន្នន័យ

នៅក្នុងចំណុចនេះ ដើម្បីបញ្ជាក់ឱ្យមានការជឿជាក់ ច្បាស់លាស់ ត្រឹមត្រូវ និងសុក្រឹត្យភាពកិច្ចការសិក្សាស្រាវជ្រាវអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឥទ្ធិពលនៃកម្មវិធីកែទម្រង់នេះ បានសម្រេចប្រើប្រាស់នូវអាលហ្វា (Cronbach's Alpha) ដើម្បីជារង្វាស់នៃភាពស្ថិតស្ថេរផ្ទៃក្នុងដែលពេលនិយមប្រើប្រាស់នៅក្នុងវិស័យចិត្តសាស្ត្រ និងធ្វើតេស្តជាធាតុដែលអាចទុកចិត្តបាននៃកម្រងសំណួរនៅក្នុងឧបករណ៍នឹងត្រូវបាន។

| ល.រ | អាល់ហ្វា (Cronbach's Alpha) | កម្រិតនៃការជឿជាក់ |
|---|---|---|
| ១ | ខ្ពស់ជាង ០.៩០ | ល្អណាស់ |
| ២ | ០.៨០-០.៨៩ | ល្អ |
| ៣ | ០.៧០-០.៧៩ | ល្អបង្គួរ |
| ៤ | ០.៦០-០.៦៩ | មធ្យម |
| ៥ | ០.៥០-០.៥៩ | ខ្សោយ |
| ៦ | ទាបជាង ០.៤៩ | មិនទទួលយក |

**តារាងទី** 2 ៖កម្រិតជឿជាក់នៃទិន្នន័យអាល់ហ្វា

| ល.រ | សម្ពតិកម្ម | ចំនួន | អាល់ហ្វា | ការវាយតម្លៃ |
|---|---|---|---|---|
| ១ | ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា | ៤ | ០.៨៥១ | ល្អ |
| ២ | ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ | ៥ | ០.៨២៧ | ល្អ |
| ៣ | ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | ៤ | ០.៧៩២ | ល្អបង្គួរ |
| ៤ | ការកសាងគណនេយ្យសមិទ្ធកម្ម | ៣ | ០.៧៩៦ | ល្អបង្គួរ |
| ៥ | ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ | ៤ | ០.៨៦១ | ល្អ |

| | | | | |
|---|---|---|---|---|
| ៦ | ឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះប្រជាពលរដ្ឋកម្ពុជា និងក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ | ៥ | ០.៨៣៩ | ល្អ |

<u>**តារាងទី 3** ៖អាល់ហ្វា (ភាពជឿជាក់នៃទិន្នន័យ)</u>

តាមរយៈលទ្ធផលដែលទទួលបាននៅក្នុងតារាងខាងលើ ភាពជឿជាក់នៃអាល់ហ្វា ចំពោះសម្មតិកម្មទី១ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកាគឺ ០.៨៥១, សម្មតិកម្មទី២ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ គឺ ០.៨២៧ សម្មតិកម្មទី៣ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយគឺ ០.៧៩២, សម្មតិកម្មទី៤ ការកសាងគណនេយ្យសមិទ្ធកម្ម គឺ ០.៧៩៦, សម្មតិកម្មទី៥ គឺ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ គឺ ០.៨៦១, និងសម្មតិកម្មទី៦ ឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះប្រជាពលរដ្ឋកម្ពុជា និងក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ គឺ ០.៨៣៩។ ជារួម ចំពោះភាពជឿជាក់នៃសម្មតិកម្មទាំង ៦ គឺល្អ។ ដូច្នេះភាពជឿជាក់នៃការវាយតម្លៃចំពោះសម្មតិកម្មបង្ហាញពីភាពទុកចិត្ត ចំពោះកម្រងសំណួរដែលបានដាក់ជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

# ជំពូកទី៥
# ការវិភាគទិន្នន័យ

## ៥.១.សេចក្ដីផ្ដើម

គោលបំណងនៃជំពូកនេះ គឺដើម្បីធ្វើការវិភាគទៅលើទិន្នន័យដែលបានប្រមូលពីអគ្គ-លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ដោយជំពូកនេះ ត្រូវបានបែងចែកជា ៣ ផ្នែកសំខាន់ៗ រួមមាន ផ្នែកទី១ វិភាគអំពីអត្តសញ្ញាណអ្នកឆ្លើយតប, ផ្នែកទី២ វិភាគពីមធ្យមមេគុណដើម្បីកំណត់រកភាពលម្អៀងនៃរង្វាស់វិភាគតាម Regression ដើម្បី កំណត់ទំនាក់ទំនងរបស់អថេរមិនឯករាជ្យ និងអថេរឯករាជ្យ និងចុងក្រោយជាការបកស្រាយលទ្ធផល។

## ៥.២. ពត៌មានទូទៅរបស់អ្នកផ្ដល់សម្ភាសន៍

បន្ទាប់ពីបានចុះស្រង់មតិពីមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យើងទទួលបានអ្នករួមផ្ដល់ចម្លើយ និងមតិយោបល់រហូតទៅដល់ចំនួន ៥០រូប តំណាងនៃមន្ត្រីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចំនួន ៥០ រូប ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

### ៥.២.១ ភេទរបស់អ្នកផ្ដល់សម្ភាសន៍

តាមសម្រង់មតិដែលទទួលបានពីមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៥០ រូប ក្នុងនោះ ភេទបុរសមានចំនួន ២៨រូប បើគិតជាភាគរយស្មើនឹង ៥៦% និងភេទស្រីមានចំនួន ២២ រូប បើគិតជាភាគរយស្មើនឹង ៤៤%។




**ក្រាហ្វិកទី 1** ៖ទិន្នន័យភេទរបស់អ្នកផ្ដល់សម្ភាសន៍

### ៥.២.២ អាយុរបស់អ្នកផ្តល់សម្ភាសន៍

ក្រោយការស្រង់មតិបានបង្ហាញថា មន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានអាយុចន្លោះពី ១៨-២៥ ឆ្នាំ មានចំនួន ៩រូប បើគិតជាភាគរយស្មើនឹង ១៧%។ អាយុចន្លោះពី ២៥-៣៥ ឆ្នាំ មានចំនួន ២៤រូប បើគិតជាភាគរយស្មើនឹង ៤៧%។ អាយុចន្លោះពី ៣៥-៤៥ ឆ្នាំ មានចំនួន ១៨ រូប បើគិតជាភាគរយស្មើនឹង ៣៦%។




<u>ក្រាហ្វិកទី 2 ៖ ទិន្នន័យអាយុរបស់អ្នកផ្តល់សម្ភាសន៍</u>

### ៥.២.៣ មុខរបររបស់អ្នកផ្តល់សម្ភាសន៍

តាមរយៈការស្រង់មតិរួចមកបង្ហាញថា ការឆ្លើយតបរបស់មន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្ហាញថាមុខរបររបស់អ្នកផ្តល់សម្ភាសន៍ដែលមានមុខរបរជាមន្ត្រីរាជការមានចំនួន ៥០ រូប បើគិតជាភាគរយស្មើនឹង ១០០%។

## ៥.៣.ការវាយតម្លៃកត្តាដែលមានឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

តាមរយៈលទ្ធផលនៃការស្រង់មតិពីមន្ត្រីចំនួន **៥០** រូប ពីអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងបានបង្ហាញថាឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ដែលមានមធ្យមភាគ **៤.១៧** និងបម្រែបម្រួលស្តង់ដា **០.៥២** គឺជាកត្តាដែលបានឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្តល់នូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ ការបន្តពង្រឹងភាពជឿទុកចិត្ត

នៃថវិកា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យសមិទ្ធកម្ម និងការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ បានចូលរួមបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាបន្តបន្ទាប់។

| **សមិទ្ធិកម្ម** | **មធ្យមភាគ** (Mean) | **បម្រែបម្រួលស្តង់ដា** (SD) |
|---|---|---|
| ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា | 4.07 | 0.51 |
| ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ | 4.18 | 0.57 |
| ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | 4.11 | 0.48 |
| ការកសាងគណនេយ្យសមិទ្ធកម្ម | 4.10 | 0.47 |
| ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ | 4.23 | 0.54 |
| ឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ | 4.34 | 0.55 |
| **សរុប** | **4.17** | **0.52** |

**តារាងទី 4** ៖មធ្យមភាគ និងបម្រែបម្រួលស្តង់ដានៃសមិទ្ធិកម្ម

**ស្តង់ដាវាយតម្លៃ**

១.មិនយល់ស្របខ្លាំង ២.មិនយល់ស្រប ៣.មិនសម្រេចចិត្ត ៤.យល់ស្រប ៥.យល់ស្របខ្លាំង

## ៥.៤.ឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ការវិភាគសមីការ Regression ការវិភាគម៉ូដែល ការវិភាគ ANOVA និងការវិភាគ Regression Coefficients ដែលមានលក្ខខណ្ឌឈានទៅរកភាពល្អប្រសើរនៃទិន្នន័យ។

ដើម្បីឈានទៅដល់ការបកស្រាយលើទិន្នន័យដែលទទួលបានតាមរយៈការវិភាគ ការសិក្សានេះនឹងបង្ហាញ ពីចំណុចសំខាន់នៃការគណនា និងការបកស្រាយលើអថេរនីមួយៗ ដូចជាអថេរឯករាជ្យ រួមមានការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យសមិទ្ធកម្ម ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ។

| អថេរពឹងផ្អែក | Multiple R = 0.951<br>R Square = 0.904<br>R-Adjust = 0.888<br>F =56.349<br>Sig=0.000 | | | | |
|---|---|---|---|---|---|
| **អថេរឯករាជ្យ** | Regression Coefficients | t-value | Sig | Collinearity | |
| | | | | Tolerance | VIF |
| ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា | 0.532 | 4.500 | 0.000 | 0.687 | 1.455 |
| ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ | 0.752 | 6.000 | 0.000 | 0.445 | 2.245 |
| ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | 0.872 | 6.500 | 0.000 | 0.241 | 4.145 |
| ការកសាងគណនេយ្យសមិទ្ធកម្ម | 0.671 | 5.500 | 0.000 | 0.341 | 2.936 |
| ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ | 1.130 | 18.000 | 0.000 | 0.663 | 1.500 |

**តារាងទី 5 ៖ការវិភាគតាមសមីការ**

យោងតាមលទ្ធផលនៃតារាងទី៥ ខាងលើ ដែលបានមកពីការសម្រង់មតិមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៥០រូប បានបង្ហាញថា Multiple R=0.៩៥១ សម្មតិកម្មទាំង ៥ រួមមាន ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យសមិទ្ធកម្ម ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ ពិតជាមានកម្លាំងទំនាក់ទំនង ឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋបានចំនួន ៩៥.១០%។

ជាមួយគ្នានេះ R Square = 0.៩០៤ គឺតំណាងឱ្យម៉ូដែលនៃ Regression ដែលបង្ហាញពីទំនាក់ទំនងរវាងបម្រែបម្រួលគម្លាតស្តង់ដា (SD) រវាងអថេរឯករាជ្យជាមួយ អថេរពឹងផ្អែក ពោលគឺអថេរពឹងផ្អែកត្រូវបានពន្យល់ដោយអថេរឯករាជ្យបានចំនួន ៩0.៤%។ នោះមានន័យថា មានអថេរឯករាជ្យចំនួន ៩.៦% ដែលមិនបានលើកមកនិយាយក្នុងម៉ូដែល។ ដូច្នេះចំនួន ៩.៦% ហៅថា Distribution terms ឬ Error terms។

ចំណែកឯ F=៥៦.៣៤៩, P = 0.000<0.0១ មានន័យថាតម្លៃ F មានសារៈសំខាន់នៅកម្រិត ១%។ មានន័យថាអថេរឯករាជ្យ (ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យសមិទ្ធកម្ម ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ) បានចូលរួមជះឥទ្ធិពលដល់អថេរពឹងផ្អែក(ឥទ្ធិពលកម្មវិធីកែទម្រង់ការ

គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ)។

**ក្រៅពីនេះលទ្ធផលនៃ Regression Coefficients បានបង្ហាញដូចខាងក្រោម៖**

**១.ការបន្តរពង្រឹងភាពជឿទុកចិត្តនៃថវិកា**

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.532, t=4.500, p-value=0.00 < 1% មានន័យថាអថេរឯករាជ្យ មានទំនាក់ទំនងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ សម្មតិកម្មទី១ ៖ ការបន្តរពង្រឹងភាពជឿទុកចិត្តនៃថវិកា ដែលការបន្តរពង្រឹងភាពជឿទុកចិត្តនៃថវិកាមានឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ "**ត្រូវទទួលយក**"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ការបន្តរពង្រឹងភាពជឿទុកចិត្តនៃថវិកានៃកម្មវិធីកែទម្រង់ មានឥទ្ធិពលដូចជា៖

- ការបង្កើនការប្រមូលចំណូលរបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល អាចធានាការចំណាយជាតិ និងកាត់បន្ថយបំណុលសាធារណៈ
- ការកែលម្អការអនុវត្តថវិការបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល អាចឱ្យការចំណាយអាចទូទាត់តាមដំណាក់កាលត្រីមាសនៃឆ្នាំ មានប្រាក់ក្នុងការទូទាត់ និងអាចបិទបញ្ចប់ចំណាយត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ N+១
- ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល បានផ្តល់ព័ត៌មានគម្រោង និងឥណទានលទ្ធកម្មសាធារណៈ អាចប្រើប្រាស់ប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង និងអាចធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈតាមរយៈកម្មវិធី FMIS
- ការគ្រប់គ្រងបន្ទុកសារពើពន្ធរបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល អាចឱ្យការវិភាគនិងរាយការណ៍បានគ្រប់គ្រងជ្រោយ និងអាចត្រួតពិនិត្យ វាស់វែង និងវាយតម្លៃច្បាស់លាស់។

**២.ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ**

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.752, t=6,000, p-value=0.00 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ សម្មតិកម្មទី២ ៖ ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ដែលការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុមានឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ "**ត្រូវទទួលយក**"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុនៃកម្មវិធីកែទម្រង់ មានឥទ្ធិពលដូចជា៖

- ការធ្វើស្វ័យប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្មវិធីកែទម្រង់ បានផ្តល់នូវការប្រើប្រាស់មុខងារប្រព័ន្ធFMIS, ផ្តល់នីតិវិធីសម្រាប់អនុវត្តនៅអង្គភាពថវិកាថ្នាក់ជាតិថវិកា និងថ្នាក់ក្រោមជាតិ, ទិន្ន័យមានភាពគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់ និងមានភាពទំនើបកម្ម។

- ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងច្បាប់ទូទាត់របស់កម្មវិធីកែទម្រង់ធ្វើ បានផ្តល់នូវការបិទបញ្ជីគណនេយ្យទាន់ពេលវេលា ស្របតាមស្តង់ដាគណនេយ្យសាធារណៈ និងផ្តល់របាយការណ៍ជូនភាគីពាក់ព័ន្ធទាន់ពេលវេលា។
- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់កម្មវិធីកែទម្រង់ អាចឱ្យក្រសួងស្ថាប័ន-ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក និងខណ្ឌអាចការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធ SRMIS ហើយប្រព័ន្ធ SRMIS អាចគ្រប់គ្រងបណ្ណសម្គាល់កម្មសិទ្ធិគ្រប់ទីតាំងទាំងអស់។
- ការគ្រប់គ្រងបំណុលសាធារណៈរបស់កម្មវិធីកែទម្រង់ អាចឱ្យរាជរដ្ឋាភិបាលអាចគ្រប់គ្រងបំណុលសាធារណៈ និងមានរបាយការណ៍តាមដានជាក់លាក់ក្នុងរង្វង់ ៣ខែ បន្ទាប់ពីត្រីមាសនីមួយ។
- ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណរដ្ឋបាល និងសហគ្រាសសាធារណៈរបស់កម្មវិធីកែទម្រង់ អាចជួយឱ្យរាជរដ្ឋាភិបាលពិនិត្យ ពិភាក្សា និងផ្តលយោបល់ជូនគ្រឹះស្ថានសាធារណរដ្ឋបាល និងសហគ្រាសសាធារណៈទាន់ពេលវេលាស្របតាមយុទ្ធសាស្ត្រកំណត់។

**៣.ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.872, t=6.500, p-value=0.00 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត ១%។ យោងតាមលទ្ធផលនេះ សម្មតិកម្មទី៣ ៖ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដែលមានឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ "**ត្រូវទទួលយក**"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថាការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនៃកម្មវិធីកែទម្រង់មានឥទ្ធិពលដូចជា៖

- ការកែលម្អការរៀបចំផែនការថវិការយៈពេលមធ្យម (MTFF) របស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋាភិបាលវាយតម្លៃគុណភាពផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ន ក្នុងការអនុម័តរាយការណ៍ជូនអង្គនីតិប្បញ្ញត្តិ និងការផ្សព្វផ្សាយ
- ការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈរបស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋាភិបាលបង្កើតយន្តការអនុវត្ត គ្រប់គ្រង និងការវាយតម្លៃលើការវិនិយោគសាធារណៈ
- ការកែលម្អប្រសិទ្ធភាពនៃការគ្រោងថវិការបស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋាភិបាលរៀបចំគម្រោងថវិកាប្រចាំឆ្នាំ តាមដានត្រួតពិនិត្យបន្ថែមលើថវិកាក្រសួងស្ថាប័ន និងពិនិត្យលើថវិកាផ្សារភ្ជាប់នឹងគោលនយោបាយ
- ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំនិងចរចារគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការធ្វើវិមជ្ឈការធនធានហិរញ្ញវត្ថុជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៤.ការកសាងគណនេយ្យសមិទ្ធកម្ម**

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=0.671, t=5.500, p-value=0.000 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត ១%។ យោងតាមលទ្ធផលនេះ សម្មតិកម្មទី៤ ៖ ការកសាងគណនេយ្យសមិទ្ធកម្ម ដែលការកសាងគណនេយ្យសមិទ្ធកម្មនយោបាយ ដែលមានឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ "**ត្រូវទទួលយក**"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ការកសាងគណនេយ្យសមិទ្ធកម្មនៃកម្មវិធីកែទម្រង់មានឥទ្ធិពលដូចជា៖

- ការរៀបចំវិធាន និងនីតិវិធីនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មរបស់កម្មវិធីកែទម្រង់ ផ្តល់នូវក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម និងប្រព័ន្ធតាមដាន និងវាយតម្លៃ
- ការកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យរបស់កម្មវិធីកែទម្រង់ អាចឱ្យក្រសួង-ស្ថាប័នកំណត់ក្របខ័ណ្ឌ វិធាន តួនាទី និងភារកិច្ចលើការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង
- ការលើកម្ពស់តម្លាភាពថវិការបស់កម្មវិធីកែទម្រង់ បានផ្តល់នូវសូចនាករចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុកើនពិន្ទុចំណាត់ថ្នាក់ថវិកា។

## ៥.ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ

លទ្ធផលនៃការវិភាគសមីការ Regression បានបង្ហាញថា b=1.130, t=18.000, p-value=0.00 < 1% មានន័យថាអថេរឯករាជ្យ ពិតជាមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយអថេរពឹងផ្អែកនៅកម្រិត១%។ យោងតាមលទ្ធផលនេះ សម្មតិកម្មទី៥ ៖ ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗដែលការកសាងគណនេយ្យសមិទ្ធកម្មនយោបាយ ដែលការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ មានឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ "**ត្រូវទទួលយក**"។ ហេតុដូច្នេះ យើងអាចសន្និដ្ឋានបានថា ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗនៃកម្មវិធីកែទម្រង់មានឥទ្ធិពលដូចជា៖

- ការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមត្ថភាពរបស់អង្គភាពក្នុងការអនុវត្តកម្មវិធីកែទម្រង់ អាចឱ្យក្រសួង-ស្ថាប័នបានរៀបចំដឹកនាំកិច្ចប្រជុំលើការងារកែទម្រង់ទៀងទាត់, ការរៀបចំផែនការសកម្មភាព និងរបាយការណ៍ប្រចាំ
- ការជានាចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្មវិធីកែទម្រង់ អាចឱ្យប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពមានដំណើរការល្អ
- ការសម្របសម្រួលកម្មវិធីកែទម្រង់ ៣បូក១ របស់កម្មវិធីកែទម្រង់ អាចឱ្យរាជរដ្ឋាភិបាល អាចរៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពរួមជាទៀងទាត់, ការរៀបចំ និងអនុវត្តលក្ខខណ្ឌយោងការងារមន្ត្រី, និងការធ្វើការត្រួតពិសនិត្យសមិទ្ធកម្មការងាររបស់មន្ត្រី

- ការកែលម្អសមិទ្ធកម្មការងាររបស់មន្ត្រីរាជរដ្ឋាភិបាលរបស់កម្មវិធីកែទម្រង់ អាចឱ្យគ្រប់ក្រសួង-ស្ថាប័នរៀបចំ និងអនុវត្តក្របខ័ណ្ឌគ្រប់គ្រងប្រើប្រាស់ប្រាក់រង្វាន់ ដោយផ្សារភ្ជាប់ទៅនឹងសមិទ្ធកម្មការងារមន្ត្រីរបស់អង្គភាពសាម៉ី។

ដូច្នេះ ក្នុងចំណោមសម្មតិកម្មទាំង ៥ ខាងលើ សម្មតិកម្មចំនួន ៥ បានបង្ហាញថាសុទ្ធសឹងតែជាកត្តាសំខាន់ ដែលមានការជះឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ។

# ជំពូកទី ៦
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៦.១.សេចក្តីផ្តើម

ជំពូកនេះនឹងផ្តោតទៅលើការសង្ខេបដើម្បីកំណត់នូវចំណុចសំខាន់ៗ នៃឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីការស្រាវជ្រាវ និងការសន្និដ្ឋាន។ ជំពូកដដែលនេះ ត្រូវបានបែងចែកជា ៣ ផ្នែកតូចៗ ដូចជា៖ ផ្នែកទី១ ការសង្ខេបអំពីលទ្ធផលផ្នែកទី២ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ និងផ្នែកទី៣ ការស្រាវជ្រាវអនាគត។

## ៦.២ សង្ខេបលទ្ធផលដែលរកឃើញ

ផ្អែកតាមលទ្ធផលពីការចុះស្រង់មតិពីមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបង្ហាញពីឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ តាមរយៈការវិភាគលើសម្មតិកម្មទាំង ៥ ដែលជាកត្តាឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះស្ថាប័នសាធារណៈ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា Mean=4.07, SD=0.52, ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ Mean=4.18, SD=0.57, ទីការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ Mean=4.11, SD=4.10, ការកសាងគណនេយ្យសមិទ្ធកម្ម Mean=4.10, SD=0.47 និងការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ ដែលអាចធ្វើការសន្និដ្ឋានបានថា មធ្យមភាពនៃសម្មតិកម្មទាំង ៥ នេះ មានតម្លៃធំជាងកម្រិត ៤ (យល់ស្រប) ដែលចាត់ទុកថាជាការពេញចិត្តទាំងអស់។

## ៦.៣ សេចក្តីសន្និដ្ឋាន

ជារួម យើងអាចទាញការសន្និដ្ឋានបានពីការប្រៀបធៀបវាងចក្ខុវិស័យ យុទ្ធសាស្ត្រគោលនយោបាយកម្មវិធីកែទម្រង់ យន្តការនីតិវិធី ផែនការសកម្មភាពរួម និងបទដ្ឋាននានាទៅនឹងការអនុវត្តជាក់ស្តែង តាមរយៈការចុះស្រង់មតិយោបល់ជាមួយមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឃើញថាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផលប្រយោជន៍ចំពោះប្រជាពលរដ្ឋកម្ពុជា និងក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈ។ ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាល បន្តអនុវត្តផែនការផែនការសកម្មភាពរួម ដែលបានដាក់ចេញរួមមានការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ការកសាងគណនេយ្យសមិទ្ធកម្ម ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីសម្រេចមហិច្ឆតា **"ប្រែក្លាយប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាពីប្រព័ន្ធផ្តោតលើធាតុចូល**

**និងមានលក្ខណៈមជ្ឈការទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងមានលក្ខណៈវិមជ្ឈការស្របតាមស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិ”។**

## ៦.៤ អនុសាសន៍

កំឡុងពេលចុះស្ទង់មតិជាមួយជាមួយមន្ត្រីនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការសិក្សាលើរបាយការណ៍តាមដានត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ២០២៣ របស់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ និងឯកសារផ្សេងៗពាក់ព័ន្ធ។ សូមផ្តល់ជាអនុសាសន៍ ដើម្បីរួមចំណែកក្នុងការកែលម្អកម្មវិធីកែទម្រង់ឱ្យកាន់តែប្រសើរឡើងខាងក្រោមនេះ៖

- ស្នើសុំគ្រប់ភាគីពាក់ព័ន្ធកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គួរតែបន្តការសហការក្នុងការអនុវត្តផែនការសកម្មភាពរួមដែលបានដាក់ចេញ
- គួរតែការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកានៃកម្មវិធីកែទម្រង់ ដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងចីរភាពហិរញ្ញវត្ថុសាធារណៈ ដោយផ្តល់អាទិភាពបន្ទាន់លើការងារពង្រឹងការប្រមូល ការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា
- គួរតែការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ដើម្បីការពង្រឹងប្រសិទ្ធភាពថវិកា និងគណនេយ្យភាពហិរញ្ញវត្ថុ នៅគ្រប់កម្រិតទាំងកម្រិតនៃការត្រួតពិនិត្យហិរញ្ញវត្ថុ កម្រិតនៃការគ្រប់គ្រងសាច់ប្រាក់ និងកម្រិតនៃការអនុវត្តកម្មវិធី
- គួរតែការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដើម្បីការឆ្លុះបញ្ចាំងបានកាន់តែល្អប្រសើរឡើងនូវអាទិភាពសំខាន់ៗ របស់រាជរដ្ឋាភិបាល ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្ត
- គួរតែការកសាងគណនេយ្យសមិទ្ធកម្ម ដើម្បីកែលម្អការគ្រប់គ្រងការចាត់ចែង និងការប្រើប្រាស់ធនធានហិរញ្ញវត្ថុសាធារណៈប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព
- គួរតែការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ ដើម្បីការជំរុញវិមជ្ឈការហិរញ្ញវត្ថុ ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនិងលក្ខខណ្ឌយោងការងារមន្ត្រីសាធារណៈទូទាំងប្រទេសសម្រាប់អនុវត្តការពិនិត្យសមិទ្ធកម្មការងារ ការផ្តល់ការលើកទឹកចិត្ត និងការអភិវឌ្ឍគុណវឌ្ឍិរបស់មន្ត្រី។

## ៦.៥ ការស្រាវជ្រាវនាអនាគត

តាមរយៈការសិក្សាស្រាវជ្រាវនាពេលបច្ចុប្បន្ន ខ្ញុំសង្កេតឃើញថាទិន្នន័យ និងព័ត៌មានមួយចំនួនធំៗ គឺមិនមានផ្សព្វផ្សាយជាសាធារណៈនោះទេ ដែលជាឧបសគ្គដ៏ធំមួយដើម្បីធ្វើការវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ។ ដូច្នេះដើម្បីឱ្យការសិក្សានាពេលអនាគារកាន់តែមានភាពពិស្តារ និងការធ្វើបច្ចុប្បន្នភាពទៅលើទិដ្ឋភាពជាក់ស្តែង ការសិក្សានាពេលអនាគត់ត្រូវបន្ថែម៖

- ប្រសិទ្ធភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ ស៊ើបអង្កេតផលប៉ះពាល់រយៈពេលវែងនៃកម្មវិធីកំណែទម្រង់ ដែលកំពុងបន្តលើអភិបាលកិច្ច តម្លាភាព និងការផ្តល់សេវាសាធារណៈ
- សមាហរណកម្មបច្ចេកវិទ្យា៖ សិក្សាអំពីសក្តានុពលនាពេលអនាគតនៃឧបករណ៍ឌីជីថល និងវេទិការដ្ឋាភិបាលអេឡិចត្រូនិកក្នុងការលើកកម្ពស់ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- និរន្តរភាពបំណុលសាធារណៈ៖ ស្វែងរកយុទ្ធសាស្ត្រពាក់ព័ន្ធសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ និងការគ្រប់គ្រងបំណុលថ្មី
- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការគ្រប់គ្រងវិបត្តិ៖ វិភាគពីរបៀបដែលប្រព័ន្ធកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងរបស់កម្ពុជា អាចអនុវត្ត និងការត្រៀមខ្លួន ដើម្បីឆ្លើយតបកាន់តែប្រសើរឡើងចំពោះវិបត្តិសេដ្ឋកិច្ច ឬសង្គ្រាម ឬវិបត្តិសុខភាពនាពេលអនាគតដូចជា COVID-19 ជាដើម
- គំនិតផ្តួចផ្តើមកសាងសមត្ថភាព៖ ស្រាវជ្រាវពីប្រសិទ្ធភាពនៃកម្មវិធីរបស់រាជរដ្ឋាភិបាលក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវជំនាញគ្រប់គ្រងហិរញ្ញវត្ថុរបស់បុគ្គលិកផ្នែកសាធារណៈ
- វិមជ្ឈការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ ដកសពិសោធន៍ពីរបៀបបេកិច្ចកការងាររបស់រាជរដ្ឋាភិបាលមូលដ្ឋានក្នុងប្រទេសកម្ពុជា អាចធ្វើឱ្យប្រសើរឡើងនូវការអនុវត្ត និងការគ្រប់គ្រងហិរញ្ញវត្ថុ
- ស្នើសុំថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈផ្តល់ឱ្យកាសឱ្យនិស្សិតអាចចូលចុះកម្មសិក្សាផ្ទាល់ ដើម្បីរៀនសូត្រនិងដកស្រង់ យកពិសោធន៍ ក៏ដូចជាការស្វែងរកឯកសារជាក់ស្តែងនៃកម្មវិធីកែទម្រង់នេះ។

# ឯកសារយោង


- យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ឆ្នាំ២០២៣
- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ២០១៨
- កម្មវិធីកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី១ ឆ្នាំ២០០៤
- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី២ ឆ្នាំ២០០៩
- ចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី៣ ឆ្នាំ ២០១៦
- ចក្ខុវិស័យ និងយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់ទី៤ ២០២៣-២០២៧ ឆ្នាំ២០២៣
- ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកែទម្រង់ ៣ បូក ១, រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០២២
- ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកែទម្រង់ ៣ បូក ១, រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ២០២២
- Allen, R., & Tommasi, D. (2001). *Managing Public Expenditure: A Reference Book for Transition Countries*. OECD Publishing.
- Andrews, M., Cangiano, M., Cole, N., de Renzio, P., Krause, P., & Seligmann, R. (2014). Budget credibility in practice. *Placeholder citation - replace with actual reference*.
- Andrews, M., Pritchett, L., & Woolcock, M. (2017). *Building State Capability: Evidence, Analysis, Action*. Oxford University Press.
- Bovens, M., Schillemans, T., & Goodin, R. E. (2008). Public Accountability. In *The Oxford Handbook of Public Accountability*. Oxford University Press.
- Cangiano, M., Curristine, T., & Lazare, M. (2013). *Public Financial Management and Its Emerging Architecture*. International Monetary Fund.
- Schick, A. (1998). Why Most Developing Countries Should Not Try New Zealand's Reforms. *The World Bank Research Observer*, 13(1), 123–131.
- World Bank. (2013). *Public Financial Management Reform in Post-Conflict Countries*. World Bank Publications.
- Google. (2024). *Survey on online learning preferences*. Google Forms. https://forms.google.com
- IBM, ( 2017 ) IBM SPSS Statistics 25 Brief Guide
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៩-២០២៥
- យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ២០១៩ -២០២៥
- យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈឆ្នាំ២០១៩-២០២៥
- យុទ្ធសាស្ត្រគៀរគរចំណូល ២០១៩-២០២៣

- ផែនការយុទ្ធសាស្ត្រតម្រង់ទិសនីតិវិធីអនុវត្តការងារតាមប្រព័ន្ធ FMIS ២០២០-២០២៥
- សន្ធានុក្រមស្តីពីការកែទម្រង់ប្រព័ន្ធថវិកា ឆ្នាំ២០២១ ( https://lexicon-gdb.legalcouncilmef .com/home )
- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ច្បាប់ស្តីពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ព្រះរាជក្រឹត្យ លេខ នសរកត១២១៣១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើត
  គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អនុក្រឹត្យលេខ ២៣. អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- អនុក្រឹត្យលេខ ២៤ អនុក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ អនុក្រឹត្យស្តីពការរៀបចំនឹងប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ប្រកាសស្តីពីការបង្កើតគណៈកម្មការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ១២២ សហវ.ប្រក ប្រកាសស្តីពីការបង្កើតការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលខ ១២២ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈឆ្នាំ២០០៨ប្រកាសស្តីពីការបង្កើតការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ១២០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ប្រកាសស្តីពីការកែសម្រួល ២១៨ សហវ.ប្រក ប្រកាសស្តីពីការបង្កើតគណៈកម្មការកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ២១៩ សហវ.ប្រក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៩ ប្រកាសស្តីពីការបង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការដើម្បីអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ប្រកាសលេខ ២៤២ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ភូមិសាស្ត្រនៃមាតិកាថវិកា
- ប្រកាសលេខ ០៤៨ សហវ សគហ សេចក្តីសម្រេច ស្តីពីការដាក់ឱ្យអនុវត្តវិធីសាស្ត្រវាយតម្លៃ និងការកំណត់ទម្ងន់ចង្កោម គោលបំណង និងផ្នែកនៃក្របខណ្ឌផែនការសកម្មភាពរួម
- ប្រកាសលេខ ៨៥៦ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងចាប់ផ្តើមអនុវត្តអង្គភាពថវិកា
- ទស្សនាទានស្តីអំពីទិសដៅយុទ្ធសាស្ត្រនៃកំណែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ២០១៣-២០២០
- ប្រកាសលេខ ១៨៩ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់ក្រោមជាតិនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ២១១ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តមាតិការគណនីនៃប្លង់គណនេយ្យថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- ប្រកាសលេខ ៧២០ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងអង្គភាពថវិកា
- សារាចរណ៍ណែនាំលេខ ០០៦ សហវ. សារាចរស្តីពីការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សារាចរណ៍ណែនាំលេខ ០៩ សវ សារាចរ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការងារគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ១៣០៩ សហវ.ប្រក ប្រកាសស្តីពីការតែងតាំងមន្ត្រីរាជការ
- អនុក្រឹត្យលេខ ៤៦៨ អនក្រ បក អនុក្រឹត្យស្តីពីការបង្កើតបៀវត្សមូលដ្ឋានរបស់មន្ត្រីរាជការនៃក្របខ័ណ្ឌ ឃ ក្របខ័ណ្ឌគ ឋានន្តរស័ក្តិទី២ និង ក្របខ័ណ្ឌគ ឋានន្តរស័ក្តិទី២
- ប្រកាសលេខ ១៩១១ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី
- ប្រកាសលេខ ០៦៨ សហវ.ប្រក ប្រកាសស្តីពីការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ
- ប្រកាសលេខ ១៥៨៩ សហវ.ប្រក ប្រកាសស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តប្រាក់បេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់ថ្នាក់ជាតិ
- ប្រកាសលេខ ២២៣ សហវ.ប្រក ប្រកាសស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដ្ឋាន
- ប្រកាសលេខ ០៤៨ សហវ សគហ សេចក្តីសម្រេច ស្តីពីការដាក់ឱ្យអនុវត្តវិធីសាស្ត្រវាយតម្លៃ និងការកំណត់ទម្ងន់ចង្កោម គោលបំណង និងផ្នែកនៃក្របខណ្ឌផែនការសកម្មភាពរួម

# ឧបសម្ព័ន្ធ

## កម្រងសំណួរវាយតម្លៃ

## ស្តីពីឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជារបស់មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ការស្រង់មតិនេះត្រូវបានរៀបចំឡើងដើម្បីសិក្សាអំពីឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។ កម្រងសំណួរនេះ គឺរៀបចំឡើងក្នុងគោលបំណងសិក្សាស្រាវជ្រាវ ដើម្បីអាចឈានទៅបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញរដ្ឋបាលសាធារណៈ នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។ សូមស្នើសុំ អនុវត្តតាមការណែនាំ និងផ្តល់មតិយោបល់ និងចម្លើយស្របទៅតាមស្ថានភាពពិតប្រាកដដោយស្មោះត្រង់។

*ចម្លើយ និងមតិយោបល់នេះនឹងត្រូវបានរក្សាការសម្ងាត់។

**សេចក្តីណែនាំ**

សូមគូសសញ្ញា (√)នៅក្នុងប្រអប់ចម្លើយ ឬបំពេញព័ត៌មានដែលស្នើសុំឱ្យបានត្រឹមត្រូវ

សូមគូសរង្វង់លេខណាមួយដែលជាចំណាត់ថ្នាក់ សម្រាប់លោកអ្នកគិតថា វាត្រឹមត្រូវតាមស្ថានភាពពិតប្រាកដ។

១.មិនយល់ស្របខ្លាំង ☐

២.មិនយល់ស្រប ☐

៣.មិនសម្រេចចិត្ត ☐

៤.យល់ស្រប ☐

៥.យល់ស្របខ្លាំង ☐

**មន្ត្រីបម្រើការងារនៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**១.ព័ត៌មានទូទៅ**

១.អាយុ: ១.១៨-២៥ ☐ ,២.២៥-៣៥ ☐ ,៣.៣៥-៤៥ ☐ ,៤.>45 ☐

២.ភេទ: ១.ប្រុស ☐ .២.ស្រី ☐

៣.មុខរបរ: ១.មន្ត្រីរាជការ ☐ ២.អាជីករ ☐ ៣.បុគ្គលិកក្រុមហ៊ុន ☐

៤.ផ្សេងៗ ☐

**២.ការបន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា**

១.ការបង្កើនការប្រមូលចំណូលរបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល អាចធានាការចំណាយជាតិ និងកាត់បន្ថយបំណុលសាធារណៈ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

២.ការកែលម្អការអនុវត្តថវិការបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល អាចឱ្យការចំណាយអាចទូទាត់តាមដំណាក់កាលត្រឹមាសនៃឆ្នាំ មានប្រាក់ក្នុងការទូទាត់ និងអាចបិទបញ្ចប់ចំណាយត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ N+1។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៣.ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល បានផ្តល់ព័ត៌មានគម្រោង និងឥណទានលទ្ធកម្មសាធារណៈ, អាចប្រើប្រាស់ប្រើប្រាស់វិធីសាស្ត្រប្រកួតប្រជែង, និងអាចធ្វើវិមជ្ឈការលទ្ធកម្មសាធារណៈតាមរយៈកម្មវិធី FMIS។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៤.ការគ្រប់គ្រង់បន្ទុកសារពើពន្ធរបស់កម្មវិធីកែទម្រង់ធ្វើឱ្យរាជរដ្ឋាភិបាល អាចឱ្យការវិភាគ និងរាយការណ៍បានគ្រប់គ្រងជ្រោយ និងអាចត្រួតពិនិត្យ វាស់វែង និងវាយតម្លៃច្បាស់លាស់។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

## ៣.ការបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ

១.ការធ្វើស្វ័ប្រវត្តិកម្មប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្មវិធីកែទម្រង់ បានផ្តល់នូវការប្រើប្រាស់មុខងារប្រព័ន្ធFMIS, ផ្តល់នីតិវិធីសម្រាប់អនុវត្តនៅអង្គភាពថវិកាថ្នាក់ជាតិ ថវិកា និងថ្នាក់ក្រោមជាតិ, ទិន្នន័យមានភាពគ្រប់គ្រាន់សម្រាប់អ្នកប្រើប្រាស់ និងមានភាពទំនើបកម្ម។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

២.ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងច្បាប់ទូទាត់របស់កម្មវិធីកែទម្រង់ធ្វើ បានផ្តល់នូវការបិទបញ្ជីគណនេយ្យទាន់ពេលវេលា ស្របតាមស្តង់ដាគណនេយ្យសាធារណៈ និងផ្តល់របាយការណ៍ជូនភាគីពាក់ព័ន្ធទាន់ពេលវេលា។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៣.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់កម្មវិធីកែទម្រង់ អាចឱ្យក្រសួងស្ថាប័ន-ស្ថាប័ន រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក និងខណ្ឌអាចការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមប្រព័ន្ធ SRMIS ហើយប្រព័ន្ធ SRMIS អាចគ្រប់គ្រងបណ្ណសម្គាល់កម្មសិទ្ធិគ្រប់ទីតាំងទាំងអស់។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៤.ការគ្រប់គ្រងបំណុលសាធារណៈរបស់កម្មវិធីកែទម្រង់ អាចឱ្យរាជរដ្ឋាភិបាលអាចគ្រប់គ្រងបំណុលសាធារណៈ និងមានរបាយការណ៍តាមដានជាក់លាក់ក្នុងរង្វង់ ៣ខែ បន្ទាប់ពីត្រីមាសនីមួយ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៥.ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់គ្រឹះស្ថានសាធារណរដ្ឋបាល និងសហគ្រាសសាធារណៈរបស់កម្មវិធីកែទម្រង់ អាចជួយឱ្យរាជរដ្ឋាភិបាលពិនិត្យ ពិភាក្សា និងផ្តល់យោបល់ជូនគ្រឹះស្ថានសាធារណរដ្ឋបាល និងសហគ្រាសសាធារណៈទាន់ពេលវេលាស្របតាមយុទ្ធសាស្ត្រកំណត់។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

## ៤.ការពង្រឹងប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

១.ការកែលម្អការរៀបចំផែនការថវិការយៈពេលមធ្យម (MTFF) របស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋាភិបាលវាយតម្លៃគុណភាពផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ន ក្នុងការអនុម័តរាយការណ៍ជូនអង្គនីតិប្បញ្ញត្តិ និងការផ្សព្វផ្សាយ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

២.ការកែទម្រង់ការគ្រប់គ្រងការវិនិយោគសាធារណៈរបស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋាភិបាលបង្កើតយន្តការអនុវត្ត គ្រប់គ្រង និងការវាយតម្លៃលើការវិនិយោគសាធារណៈ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៣.ការកែលម្អប្រសិទ្ធភាពនៃការគ្រោងថវិការបស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋាភិបាលរៀបចំគម្រោងថវិកាប្រចាំឆ្នាំ តាមដានត្រួតពិនិត្យបន្ថែមលើថវិកាក្រសួងស្ថាប័ន និងពិនិត្យលើថវិកាផ្សារភ្ជាប់នឹងគោលនយោបាយ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៤.ការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិរបស់កម្មវិធីកែទម្រង់ អាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំនិងចរចារគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការធ្វើវិមជ្ឈការធនធានហិរញ្ញវត្ថុជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

**៥.ការកសាងគណនេយ្យសមិទ្ធកម្ម**

១.ការរៀបចំវិធាន និងនីតិវិធីនៃប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មរបស់កម្មវិធីកែទម្រង់ ផ្តល់នូវក្របខ័ណ្ឌថវិកាព័ត៌មានសមិទ្ធកម្ម និងប្រព័ន្ធតាមដាន និងវាយតម្លៃ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

២.ការកែលម្អប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យរបស់កម្មវិធីកែទម្រង់ អាចឱ្យក្រសួង-ស្ថាប័នកំណត់ក្របខ័ណ្ឌ វិធាន តួនាទី និងភារកិច្ចលើការងារអធិការកិច្ច និងសវនកម្មផ្ទៃក្នុង។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៣.ការលើកម្ពស់តម្លាភាពថវិការបស់កម្មវិធីកែទម្រង់ បានផ្តល់នូវសូចនាករចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុកើនពិន្ទុចំណាត់ថ្នាក់ថវិកា។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

**៦.ការគាំទ្រកម្មវិធីកែទម្រង់ប្រកបដោយចីរភាព និងភាពប្រទាក់ក្រឡាគ្នានៃការកែទម្រង់ផ្សេងៗ**

១.ការលើកកម្ពស់ភាពជាអ្នកដឹកនាំ និងសមត្ថភាពរបស់អង្គភាពក្នុងការអនុវត្តកម្មវិធីកែទម្រង់ អាចឱ្យក្រសួង-ស្ថាប័នបានរៀបចំដឹកនាំកិច្ចប្រជុំលើការងារកែទម្រង់ទៀងទាត់, ការរៀបចំ

ផែនការសកម្មភាព និងរបាយការណ៍ប្រចាំត្រីមាស និងប្រចាំឆ្នាំទាន់ពេលវេលា, និងមន្ត្រីទទួលបន្ទុកការងារមានគុណវិឌ្ឍិសមស្របនឹងមុខតំណែង។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

២.ការធានាចលនាការនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្មវិធីកែទម្រង់ អាចឱ្យប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម និងគណនេយ្យភាពមានដំណើរការល្អ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៣.ការសម្របសម្រួលកម្មវិធីកែទម្រង់ ៣បូក១ របស់កម្មវិធីកែទម្រង់ អាចឱ្យរាជរដ្ឋាភិបាលអាចរៀបចំ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃផែនការសកម្មភាពរួមជាទៀងទាត់, ការរៀបចំ និងអនុវត្តលក្ខខណ្ឌយោងការងារមន្ត្រី, និងការធ្វើការត្រួតពិសនិត្យសមិទ្ធកម្មការងាររបស់មន្ត្រី។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៤.ការកែលម្អសមិទ្ធកម្មការងាររបស់មន្ត្រីរាជរដ្ឋាភិបាលរបស់កម្មវិធីកែទម្រង់ អាចឱ្យគ្រប់ក្រសួង-ស្ថាប័នរៀបចំ និងអនុវត្តក្របខ័ណ្ឌគ្រប់គ្រងប្រើប្រាស់ប្រាក់រង្វាន់ ដោយផ្សារភ្ជាប់ទៅនឹងសមិទ្ធកម្មការងារមន្ត្រីរបស់អង្គភាពសាម៉ី។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

**៧.ឥទ្ធិពលកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានផលប្រយោជន៍ចំពោះប្រជាពលរដ្ឋកម្ពុជា និងក្រសួងស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ សហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល**

១.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានផ្ដល់នូវវិធាននិងនីតិវិធីក្នុងការអនុវត្តផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័ន ដែលបានដាក់ចេញរដ្ឋមន្ត្រី ឬប្រធានស្ថាប័នដោយត្រូវសម្រេចឱ្យបាននូវសូចនាករ និងគោលដៅនៃសកម្មភាពនីមួយៗតាមការកំណត់។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

២.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតនូវយន្តការតាមដានវឌ្ឍនភាពផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័ន ជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ ឬការកែសម្រួលផែនការសកម្មភាពនៅត្រីមាសទី៣ (ការពិនិត្យឡើងវិញននិងអាចស្នើសុំកែសម្រួលតាមការចំបាច ឬពិនិត្យនិងផ្តល់យោបល់សម្រាប់អនុវត្តឆ្នាំបន្ទាប់) ដើម្បីជានាប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពផែនការសកម្មភាពដែលបានដាក់ចេញ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៣.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតយន្តការដោះស្រាយបញ្ហាប្រឈមមួយចំនួនចំពោះការអនុវត្តផែនការសកម្មភាពដោយការពិនិត្យ តាមដាន និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការកំណត់បញ្ហា ប្រឈមឱ្យបានជាក់លាក់ និងចាក់វិធានការណ៍ដោះស្រាយជាបន្ទាន់ សំដៅជានាជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានវឌ្ឍនាការប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៤.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើនសិទ្ធិសម្រេចជូនអង្គភាពថវិកា, ការធ្វើទំនើបកម្មនីតិវិធីនិងប្រតិបត្តិការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការពង្រឹងសមត្ថភាពស្ថាប័ន, ការធ្វើវិចារណកម្មមុខងារនិងភារកិច្ចអង្គភាពផ្ទៃក្នុងនៃក្រសួង ស្ថាប័ន, ការតម្រឹមលក្ខខណ្ឌយោងការងារមន្ត្រីជាមួយនឹងរចនាសម្ព័ន្ធនៃថវិកា និងការពង្រឹងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

៥.កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋរួមមានការកសាងហេដ្ឋារចនាសម្ព័ន្ធ ពង្រឹងវិស័យអប់រំ និងវិស័យសុខាភិបាល។

១.មិនយល់ស្របខ្លាំង ☐
២.មិនយល់ស្រប ☐
៣.មិនសម្រេចចិត្ត ☐
៤.យល់ស្រប ☐
៥.យល់ស្របខ្លាំង ☐

សូមថ្លែងអំណរគុណសម្រាប់ការចូលរួមសហការ និងយលព្រមឆ្លើយតបទៅនឹងសំណួរស្តីពីឥទ្ធិពលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។